ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# គោលការណ៍ណែនាំ

# ស្តីពី

# ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ

រៀបចំដោយៈ ក្រសួងផែនការ

រាជធានីភ្នំពេញ ខែកញ្ញា ឆ្នាំ២០១៨

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# រាជរដ្ឋាភិបាលកម្ពុជា

# គោលការណ៍ណែនាំ

# ស្តីពី

# ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ

រៀបចំដោយ៖ ក្រសួងផែនការ

គាំទ្រដោយ៖ CCCA

រាជធានីភ្នំពេញ ខែកញ្ញា ឆ្នាំ២០១៨

# បុព្វកថា

ប្រទេសកម្ពុជា បានរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិរបស់ខ្លួនបានចំនួន៥លើករួចមកហើយចាប់តាំងពីឆ្នាំ១៩៩៦ ហើយបច្ចុប្បន្នកំពុងអនុវត្តផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ ដែលជាផែនការអភិវឌ្ឍន៍លើកទី៥ ដែលមានចែងអំពីគោលនយោបាយនិងគោលដៅអាទិភាពរបស់រាជរដ្ឋាភិបាលដែលត្រូវអនុវត្តក្នុងរយៈពេល០៥ឆ្នាំ។ ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍របស់ប្រទេស ចាំបាច់ត្រូវរៀបចំឲ្យមានផែនការអភិវឌ្ឍន៍និងការប្តេជ្ញាចិត្តផ្នែកធនធាននៅគ្រប់កម្រិត។

នៅថ្នាក់ជាតិ ការទទួលខុសត្រូវផ្នែករៀបចំផែនការនិងថវិកាត្រូវធ្វើប្រតិភូកម្មទៅឲ្យក្រសួង ស្ថាប័ន។ ដើម្បីអនុវត្តការទទួលខុសត្រូវនេះប្រកបដោយប្រសិទ្ធភាព ក្រសួង ស្ថាប័នត្រូវរៀបចំគោលនយោបាយ យុទ្ធសាស្រ្ត និងកម្មវិធីនានាដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍តាមវិស័យរបស់ខ្លួន ដែលបានបន្សុំជាមួយផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ។ ដូចនេះ ក្រសួងផែនការផ្តួចផ្តើមរៀបចំគោលការណ៍ណែនាំសម្រាប់រៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍តាមវិស័យនេះឡើងបន្ថែមលើគោលការណ៍ណែនាំសម្រាប់រៀបចំផែនការនៅថ្នាក់ក្រោមជាតិ។ ដោយសារទំនាក់ទំនងរវាងដំណើរការរៀបចំផែនការអភិវឌ្ឍន៍វិស័យ និងផែនការថ្នាក់ក្រោមជាតិ គោលការណ៍ណែនាំទាំងពីរនេះនឹងត្រូវប្រើប្រាស់រួមគ្នាសម្រាប់វិស័យមួយចំនួន។ គោលការណ៍ណែនាំនេះក៏បានទទួលស្គាល់ថាគោលការណ៍ណែនាំអន្តរវិស័យផ្សេងទៀត ដូចជាយេនឌ័រ ការប្រែប្រួលអាកាសធាតុជាដើម ត្រូវបានរៀបចំឡើងជាឧបករណ៍បំពេញបន្ថែមសម្រាប់ដំណើរការរៀបចំផែនការទាំងមូល។

គោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍តាមវិស័យ អនុលោមតាមគោលការណ៍មូលដ្ឋាននៃការរៀបចំផែនការអភិវឌ្ឍន៍ ដូចជាការចូលរួមពេញលេញក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ ផែនការដែលផ្អែកលើភស្តុតាង បន្សុំជាមួយផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ និងចក្ខុវិស័យជាតិ ការធ្វើសមាហរណកម្មគោលនយោបាយ និងបញ្ហាអន្តរវិស័យ អាណត្តិរបស់ក្រសួង ស្ថាប័នយោងតាមសមត្ថភាពបច្ចេកទេសរបស់ខ្លួន តម្លាភាព និងប្រសិទ្ធភាពចំណាយក្នុងការផ្តល់សេវា។

ក្នុងនាមរាជរដ្ឋាភិបាលនិងក្រសួងផែនការ ខ្ញុំសូមថ្លែងអំណរគុណដល់គ្រប់អ្នកមានចំណែកពាក់ព័ន្ធទាំងអស់ ដែលបានផ្តល់ការចូលរួមចំណែកដ៏មានតម្លៃក្នុងការរៀបចំគោលការណ៍ណែនាំនេះ ជាពិសេស **ឯកឧត្តម ថេង បញ្ញាធន** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកអគ្គនាយកផែនការ និងសហការី ដែលបានរៀបចំគោលការណ៍ណែនាំនេះឡើង។ លើសពីនេះទៀត ខ្ញុំសូមថ្លែងអំណរគុណដល់UNFPA ដែលបានផ្តល់ការគាំទ្រហិរញ្ញវត្ថុដល់ក្រសួងផែនការ ជាពិសេសដលល់ការរៀបចំគោលការណ៍ណែនាំនេះ និងCCCA ដែលបានផ្តល់ការគាំទ្រផ្នែកបច្ចេកទេសក្នុងការដាក់បញ្ចូលការប្រែប្រួលអាកាសធាតុលម្អិតក្នុងគោលការណ៍ណែនាំនេះ ។

គោលការណ៍ណែនាំនេះ មានគោលបំណងគាំទ្រដល់ការរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍តាមវិស័យ ដែលមានលក្ខណៈស្តង់ដា ដែលជួយដល់ការអនុវត្តផែនការនានានិងគាំទ្រដល់ការតាមដាននិងវាយតម្លៃវឌ្ឍនភាពការអនុវត្តនិងការសម្រេចបានគោលដៅរបស់ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ និងគោលដៅអភិវឌ្ឍន៍

ប្រកបដោយចីរភាពកម្ពុជា។ ដូចនេះ ខ្ញុំសូមស្នើដល់ក្រសួង ស្ថាប័នទាំងអស់ និងអ្នកពាក់ព័ន្ធផ្សេងទៀតប្រើប្រាស់គោលការណ៍ណែនាំនេះក្នុងការរៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យរបស់ខ្លួនឲ្យមានប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ ខែកញ្ញា ឆ្នាំ២០១៨

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងផែនការ**

**ឆាយ ថន**

# មាតិកា


**បុព្វកថា** ........................................................................................ i

**មាតិកា** ........................................................................................ ii

**ជំពូកទី១៖ សេចក្តីផ្តើម** ........................................................................................ 1

១.១ ចេនាសម្ព័ន្ធនៃគោលការណ៍ណែនាំស្តីពីរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ ............ 1

១.២ សាវតា........................................................................................ 1

១.៣ មូលហេតុ........................................................................................ 2

១.៤ គោលបំណង ........................................................................................ 2

១.៥ អ្នកប្រើប្រាស់ ........................................................................................ 3

**ជំពូកទី២៖ ក្របខ័ណ្ឌស្ថាប័នសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ**.............................. 4

២.១ ក្របខ័ណ្ឌសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ........................................ 4

២.១.១ ផែនការអភិវឌ្ឍន៍រយៈពេលវែង ........................................................................ 5

២.១.២ ផែនការអភិវឌ្ឍន៍រយៈពេលមធ្យម ........................................................................ 5

២.១.៣ ផែនការអភិវឌ្ឍន៍រយៈពេលខ្លី ........................................................................ 6

២.២ ដំណើរការពិគ្រោះយោបល់និងអនុម័តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ ........................ 6

២.៣ ការរៀបចំស្ថាប័នសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ ................................ 7

**ជំពូកទី៣៖ ដំណើរការនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ** ..................................... 10

៣.១ ទម្រង់របស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ ................................................ 10

៣.៣ ដំណាក់កាលនៃការរៀបចំផ.យ.អ.វ.................................................................... 13

៣.៣ ពេលវេលាសម្រាប់រៀបចំផ.យ.អ.វ. ........................................................................ 23

**ជំពូកទី៤៖ ដំណើរការអនុវត្ត ផ.យ.អ.វ.**........................................................................ 24

៤.១ ការទទួលខុសត្រូវសម្រាប់ការអនុវត្តផ.យ.អ.វ. .................................................... 24

៤.២ សង្គតិភាពរវាងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមជាមួយផ.យ.អ.ជ.និងផ.យ.អ.វ.............. 24

៤.៣ ការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ........................................................................ 24

៤.៤ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ........................................................................ 25

## បញ្ជីរូបភាព


រូបភាពទី១ : ក្របខ័ណ្ឌសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ............................................4
រូបភាពទី២ : ដំណើរការនៃការរៀបចំផ.យ.អ.ជ. ...................................................................................6
រូបភាពទី៣ : ដំណើរការនៃការរៀបចំផ.យ.អ.វ. ...................................................................................6
រូបភាពទី៤ : ចង្វាក់លទ្ធផល ...................................................................................................19
រូបភាពទី៥ : នីតិវិធីក្នុងការត្រួតពិនិត្យតាមដានផ.យ.អ.វ. ...........................................................20


## បញ្ជីប្រអប់


ប្រអប់ទី១ : ទម្រង់ស្តង់ដារបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ ............................................9


## បញ្ជីតារាង


តារាងទី១ : ទំនាក់ទំនងរវាងគោលដៅអភិវឌ្ឍន៍សំខាន់ៗជាមួយផ.យ.អ.ជ. ......................................16
តារាងទី២ : រចនាសម្ព័ន្ធនិងមាតិការបស់តារាងក្របខ័ណ្ឌតក្កៈ .......................................................17
តារាងទី៣ : សកម្មភាពនិងពេលវេលាសម្រាប់រៀបចំផ.យ.អ.វ. ....................................................22


## បញ្ជីឧបសម្ព័ន្ធ


ឧបសម្ព័ន្ធទី១ : ម៉ាទ្រីចស្តីពីតម្រូវការចំណាយ ...........................................................................25
ឧបសម្ព័ន្ធទី២ : ម៉ាទ្រីចស្តីពីការតាមដានត្រួតពិនិត្យការអនុវត្ត ......................................................25

# ជំពូកទី១

# សេចក្ដីផ្ដើម

## ១.១ រចនាសម្ព័ន្ធនៃគោលការណ៍ណែនាំស្ដីពីរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ

គោលការណ៍ណែនាំស្ដីពីរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ មានជំពូក ដូចខាងក្រោម៖

- **ជំពូកទី១ សេចក្ដីផ្ដើម** បង្ហាញអំពីរចសម្ព័ន្ធរបស់គោលការណ៍ណែនាំស្ដីពីរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ សារតា មូលហេតុ គោលបំណង និងអ្នកប្រើប្រាស់គោលការណ៍ណែនាំស្ដីពីរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យនេះ។
- **ជំពូកទី២ ក្របខ័ណ្ឌស្ថាប័នសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ** បង្ហាញអំពីដំណើរការរៀបចំ ការពិគ្រោះយោបល់ ការអនុម័ត និងរចនាសម្ព័ន្ធសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ។
- **ជំពូកទី៣ ដំណើរការនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ** បង្ហាញអំពីរចនាសម្ព័ន្ធស្ដង់ដាសម្រាប់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ ដំណាក់កាល និងរយៈពេលសម្រាប់នៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ។
- **ជំពូកទី៤** ដំណើរការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ បង្ហាញអំពីការទទួលខុសត្រូវក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យសង្គតិភាពក្របខ័ណ្ឌចំណាយរយៈពេលមធ្យមជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ ការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ និងការតាមដានត្រួតពិនិត្យនិងវាយតម្លៃ។

## ១.២ សារតា

ក្រសួងផែនការមានតួនាទីក្នុងការផ្ដល់ការណែនាំ រៀបចំ និងគ្រប់គ្រងការរៀបចំផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ច និងគ្រប់គ្រងដំណើរការផលិតស្ថិតិជាតិសម្រាប់គាំទ្រដល់ការរៀបចំផែនការ និងសម្រាប់វាស់វែងវឌ្ឍនភាពនៃការអនុវត្តផែនការ។

ដើម្បីសម្រេចបានការអភិវឌ្ឍប្រកបដោយចីរភាព កម្ពុជាត្រូវមានការរៀបចំផែនការអភិវឌ្ឍន៍និងមានការប្តេជ្ញាចិត្តផ្នែកធនធានមនុស្សនិងហិរញ្ញវត្ថុឲ្យមានលក្ខណៈច្បាស់លាស់។ នៅថ្នាក់ជាតិ ក្រសួង ស្ថាប័នទទួលខុសត្រូវក្នុងការរៀបចំផែនការអភិវឌ្ឍន៍ និងថវិកាសម្រាប់វិស័យរបស់ខ្លួន និងសម្រាប់ថ្នាក់ក្រោមជាតិក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំសង្កាត់ ទទួលខុសត្រូវក្នុងការរៀបចំផែនការនិងថវិការបស់ខ្លួន។ ដើម្បីអនុវត្តតួនាទីនេះឲ្យមានប្រសិទ្ធភាព ក្រសួង ស្ថាប័នត្រូវរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីនានា ដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ ដែលបន្សុីជាមួយគោលនយោបាយអាទិភាព

របស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ ត្រូវគោរពតាមគោលការណ៍ណែនាំដែលចេញដោយក្រសួងផែនការ។

គោលការណ៍ណែនាំស្តីពីរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យនេះ ត្រូវបានរៀបចំឡើងដោយផ្អែកលើការវិភាគលើយន្តការរៀបចំផែនការតាមវិស័យបច្ចុប្បន្ន ដើម្បីទទួលបានជាបទពិសោធន៍និងមេរៀនល្អៗដែលមានស្រាប់ និងតម្រូវការក្នុងការរៀបចំផែនការអភិវឌ្ឍន៍របស់កម្ពុជា។

គោលការណ៍ណែនាំស្តីពីរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យនេះ អនុលោមតាមគោលការណ៍មូលដ្ឋាននៃការរៀបចំផែនការអភិវឌ្ឍន៍ ដូចជា ភស្តុតាង ការចូលរួម ស្តង់ដា និងការបន្សុីជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនិងចក្ខុវិស័យរបស់ជាតិ ការធ្វើសមាហរណកម្មបញ្ហា និងគោលនយោបាយអន្តរវិស័យ ការបំពេញតួនាទីរបស់ក្រសួង ស្ថាប័ន ដោយយោងតាមសមត្ថភាពបច្ចេកទេសនិងការគាំទ្រ តម្លាភាព និងតម្លៃសម្រាប់ថវិកាក្នុងការផ្តល់សេវា ព្រមទាំងការសមាហរណកម្មសិទ្ធិមនុស្សទៅក្នុងគោលនយោបាយ ផែនការ និងកម្មវិធីនានា។

## ១.៣ មូលហេតុ

ក្រសួង ស្ថាប័ន ត្រូវមានការយល់ដឹងអំពីគោលដៅអភិវឌ្ឍន៍របស់ជាតិ និងត្រូវរៀបចំនិងអនុវត្តផែនការយុទ្ធ-សាស្ត្រអភិវឌ្ឍន៍តាមវិស័យ ដែលបន្សុីជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ បច្ចុប្បន្ននេះ ក្រសួង ស្ថាប័នជាច្រើនពុំទាន់មានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យរបស់ខ្លួនទេ ហើយក្រសួង ស្ថាប័ន ដែលមានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យរួចហើយ ដំណើរការនៃការរៀបចំពុំទាន់ត្រឹមត្រូវតាមក្របខ័ណ្ឌការរៀបចំផែនការ និងមិនទាន់មានការបន្សុីពេញលេញជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ការបន្សុីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គឺជាបញ្ហាប្រឈមមួយដោយសារអាទិភាពដែលបានលើកឡើងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ អាចមិនមានសង្គតិភាពជាមួយអាទិភាពដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ដើម្បីដោះស្រាយបញ្ហានេះ ក្រសួងផែនការបានរៀបចំគោលការណ៍ណែនាំនេះ សម្រាប់គាំទ្រដល់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យដែលមានការបន្សុីគ្នាជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដូចជា ពេលវេលា គោលបំណង យុទ្ធសាស្ត្រ និងកម្មវិធីជាដើម។

## ១.៤ គោលបំណង

គោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យនេះ ត្រូវបានរៀបចំឡើង ក្នុងគោលបំណង ដើម្បី៖

- ផ្តល់ទម្រង់រួមមួយសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យដែលមានការបន្សុីគ្នាជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។
- សម្របសម្រួលការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យដោយផ្អែកលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងការរៀបចំផែនការយុទ្ធសាស្ត្រថវិកានិងផែនការសកម្មភាពប្រចាំឆ្នាំដោយផ្អែកលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ។

- ធានាថាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យត្រូវបានរៀបចំឡើង សម្រាប់គាំទ្រការសម្រេចបានគោលបំណងអភិវឌ្ឍន៍របស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។
- ធានាថាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យមានទម្រង់ស្តង់ដារួម និងមានពេលវេលាដូចគ្នាសម្រាប់ផែនការអភិវឌ្ឍន៍រយៈពេលមធ្យម ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងធានាថាបានដាក់បញ្ចូលបញ្ហាអន្តរវិស័យដែលបានកំណត់ក្នុងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។
- ផ្តល់ជាមូលដ្ឋានសម្រាប់រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំនៅថ្នាក់ជាតិ សម្រាប់រយៈពេលនៃផែនការ និង
- ផ្តល់ជាមូលដ្ឋានសម្រាប់ការអនុវត្ត ការតាមដានត្រួតពិនិត្យនិងវាយតម្លៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឲ្យមានប្រសិទ្ធភាពនៅតាមវិស័យ

## ១.៥ អ្នកប្រើប្រាស់

អ្នកប្រើប្រាស់គោលការណ៍ណែនាំនេះសំខាន់ៗ គឺក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធផ្សេងទៀត ដែលធ្វើការងារពាក់ព័ន្ធនឹងការរៀបចំផែនការអភិវឌ្ឍន៍តាមវិស័យ ដែលមានដូចខាងក្រោមៈ

- ក្រសួងផែនការ សម្រាប់ការផ្តល់ការណែនាំរួមដល់ដំណើរការនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ។
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ការបូកសរុបថវិការបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យតាមរយៈផែនការយុទ្ធសាស្ត្រថវិកាទៅក្នុងថវិកាជាតិ។
- សមាជិកនៃក្រុមការងារតាមវិស័យ ដែលមានតួនាទីក្នុងសម្របសម្រួល រៀបចំ តាមដាន វាយតម្លៃ និងធ្វើរបាយការណ៍ស្តីពីគោលដៅនិងចក្ខុវិស័យ ក្របខ័ណ្ឌគោលនយោបាយ ផែនការ និងការសម្រេចបាននៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យរបស់ក្រសួង ស្ថាប័ន។
- វិស័យឯកជន ដែលមានបំណងក្នុងការធ្វើសមាហរណកម្មសកម្មភាពរបស់ខ្លួនទៅក្នុងផែនការសកម្មភាពនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ។
- ដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិល ដែលត្រូវការកំណត់អាទិភាពសម្រាប់គាំទ្រដល់ការអភិវឌ្ឍតាមវិស័យ។
- គ្រឹះស្ថានសិក្សា សម្រាប់ធ្វើជាមូលដ្ឋាននៃសិក្សាស្រាវជ្រាវនានា។
- ទីប្រឹក្សា ដែលជាប់ពាក់ព័ន្ធនឹងការគាំទ្រដល់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ។

# ជំពូកទី២

# ក្របខ័ណ្ឌស្ថាប័នសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ

## ២.១ ក្របខ័ណ្ឌសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

ក្របខ័ណ្ឌសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បានកំណត់ពីគោលការណ៍ណែនាំសម្រាប់ការរៀបចំផែនការអភិវឌ្ឍន៍រយៈពេលវែងនិងមធ្យមក្នុងការសម្រេចបានចក្ខុវិស័យជាតិរួម។ ក្របខ័ណ្ឌនេះត្រូវបានអនុវត្តតាមរយៈក្របខ័ណ្ឌសម្រាប់ការរៀបចំផែនការអភិវឌ្ឍន៍រយៈពេលវែង ដែលអាចមានយ៉ាងតិចរយៈពេល១០ឆ្នាំ ដូចជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរយៈពេល១០ឆ្នាំ ក្របខ័ណ្ឌសម្រាប់ការរៀបចំផែនការអភិវឌ្ឍន៍រយៈពេលមធ្យម ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរយៈពេល៥ឆ្នាំ ព្រមទាំងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ រួមទាំងថវិកានិងផែនការសកម្មភាពប្រចាំឆ្នាំ។

រូបភាពទី១ : ក្របខ័ណ្ឌសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ



### ២.១.១ ផែនការអភិវឌ្ឍន៍រយៈពេលវែង

បច្ចុប្បន្ន កម្ពុជាពុំទាន់មានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរយៈពេលវែងទេ មានតែផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរយៈពេលមធ្យម។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរយៈពេល៥ឆ្នាំដំបូង គឺផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ២០០១-២០០៥ ហើយបច្ចុប្បន្ន គឺផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរយៈពេល១០ឆ្នាំឬវែងជាងនេះ នឹងផ្តល់ជាការតម្រង់ទិសយុទ្ធសាស្ត្រសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ៥ឆ្នាំ។

### ២.១.២ ផែនការអភិវឌ្ឍន៍រយៈពេលមធ្យម

#### *ក. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ៥ឆ្នាំ*

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ៥ឆ្នាំ គឺជាឧបករណ៍សម្រាប់កំណត់អាទិភាពរបស់គោលនយោបាយ កម្មវិធី និងសកម្មភាពនានារបស់រាជរដ្ឋាភិបាលនិងសម្រាប់កៀរគរធនធានពីប្រភពខាងក្រៅ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គ្របដណ្តប់ចំណុចដូចខាងក្រោម៖

- ទស្សនទានទូទៅស្តីពីការអភិវឌ្ឍន៍សេដ្ឋកិច្ច រួមមានការសម្រេចបានផ្នែកម៉ាក្រូសេដ្ឋកិច្ច បញ្ហាប្រឈម និងកាលានុវត្តភាពសម្រាប់ការអភិវឌ្ឍ។
- ខ្លឹមសាររបស់ផែនការដែលមានសង្គតិភាពជាមួយចក្ខុវិស័យជាតិ រួមមាន គោលនយោបាយ គោលបំណង យុទ្ធសាស្ត្រ និងអន្តរាគមន៍នានា។
- សមិទ្ធផលក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិអាណត្តិមុន
- កម្មវិធី និងគម្រោងអភិវឌ្ឍន៍អាទិភាព
- យុទ្ធសាស្ត្រនិងការរៀបចំសម្រាប់ការអនុវត្តនិងការតាមដានត្រួតពិនិត្យនិងវាយតម្លៃ
- តួនាទីរបស់អ្នកពាក់ព័ន្ធសំខាន់ៗ ដូចជា ក្រសួង ស្ថាប័ន វិស័យឯកជន ដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិល

អាទិភាព ដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិផ្តល់ជាការតម្រង់ទិសសម្រាប់ការបែងចែកធនធានសាធារណៈនិងត្រូវធ្វើការប៉ាន់ស្មានចំណាយតាមឆ្នាំ។ លើសពីនេះទៀត សូចនាករនិងចំណុចដៅប្រចាំឆ្នាំត្រូវកំណត់ឲ្យបានច្បាស់លាស់នៅក្នុងផែនការ ដើម្បីងាយស្រួលក្នុងការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃការសម្រេចបាននៃការអនុវត្តផែនការ។

#### *ខ. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ*

ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ ដែលមានសង្គតិភាពជាមួយគោលដៅអភិវឌ្ឍន៍រយៈពេលវែង។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យផ្តល់ជាការតម្រង់ទិសយុទ្ធសាស្ត្រក្នុងវិស័យខ្លួន ដែលត្រូវមានសង្គតិភាពជាមួយអាទិភាពនិងរយៈពេលរបស់ផ.យ.អ.ជ.។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យត្រូវធានាថាវិស័យមានលទ្ធភាពបំពេញតួនាទីវិស័យដូចបានកំណត់ក្នុងផ.យ.អ.ជ.។ ផែនការ

យុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យត្រូវកំណត់អំពីអន្តរាគមន៍នានា រួមមានសូចនាករធាតុចូល ធាតុចេញ និង ចំណុចដៅលម្អិត ដើម្បីសម្រេចបានគោលបំណងនីមួយៗនៅក្នុងវិស័យ។

### ២.១.៣ ផែនការអភិវឌ្ឍន៍រយៈពេលខ្លី

ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ ដែលមានសង្គតិភាពជាមួយអាទិភាពនានានៅក្នុង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យនិងផ.យ.អ.ជ.។

## ២.២ ដំណើរការពិគ្រោះយោបល់និងអនុម័តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ ត្រូវអនុលោមតាមគោលការណ៍នៃការរៀបចំផែនការអភិវឌ្ឍន៍ស្តង់ដា រួមមានភស្តុតាង (ទិន្នន័យច្បាស់លាស់) ការចូលរួម ស្តង់ដានីយកម្ម និងការបន្ស៊ីជាមួយចក្ខុវិស័យជាតិ និង ផ.យ.អ.ជ. ការបញ្ចូលបញ្ហាអន្តរវិស័យ អាណត្តិរបស់វិស័យ សមត្ថភាពនិងការគាំទ្រ ការគាំទ្រដល់សមត្ថភាព គ្រប់គ្រងនិងបច្ចេកទេស តម្លាភាព និងប្រសិទ្ធភាពចំណាយដើម្បីជៀសវាងភាពត្រួតគ្នាក្នុងការផ្តល់សេវា។ ដើម្បីធានាគោលការណ៍ទាំងនេះ ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យត្រូវធ្វើឡើងដោយគោរព តាមដំណើរពិគ្រោះយោបល់និងអនុម័តជាប្រព័ន្ធមួយ។

រូបភាពទី២ : ដំណើរការនៃការរៀបចំផ.យ.អ.ជ.




រូបភាពទី៣ : ដំណើរការនៃការរៀបចំផ.យ.អ.វ.



ដំណើរការរៀបចំផែនការត្រូវចាប់ផ្តើមដោយការចេញសារាចរដោយក្រសួងផែនការទៅគ្រប់ក្រសួង ស្ថាប័ន ដើម្បីជូនដំណឹងដល់អ្នកពាក់ព័ន្ធទាំងអស់អំពីការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងស្នើឲ្យផ្តល់ធាតុចូលរួមមានផែនការអភិវឌ្ឍន៍និងថវិកាមកក្រសួងផែនការ។ សារាចរបង្ហាញអំពីគោលការណ៍ណែនាំស្តីពីការរៀបចំផែនការ ទស្សនទានម៉ាក្រូសេដ្ឋកិច្ច វិស័យអាទិភាព ពេលវេលាសម្រាប់ផ្តល់ធាតុចូល និងលក្ខណៈវិនិច្ឆ័យសម្រាប់ការបែងចែកធនធានសម្រាប់កម្មវិធីនិងគម្រោង។ សារាចរ ក៏តម្រូវឲ្យក្រសួង ស្ថាប័នរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យដោយផ្អែកលើវិស័យអាទិភាពដែលបានកំណត់ក្នុងផ.យ.អ.ជ.។

### ដំណើរការនៃការពិគ្រោះយោបល់

ការពិគ្រោះយោបល់នានា ត្រូវទទួលបានការឯកភាពគ្នាតាមរយៈការពិគ្រោះយោបល់ដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធនៅថ្នាក់ជាតិ រួមទាំងវិស័យឯកជន ដៃគូអភិវឌ្ឍ និងសង្គមស៊ីវិល និងនៅកម្រិតម៉ាក្រូរបៀបវារៈអភិវឌ្ឍន៍ និងចំណុចដៅម៉ាក្រូសេដ្ឋកិច្ចត្រូវមានការឯកភាពគ្នាក្នុងកិច្ចពិភាក្សារវាងស្ថាប័នកណ្តាលទាំង៤ ដែលមានក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

### ក. ការពិគ្រោះយោបល់នៅកម្រិតវិស័យ

នៅកម្រិតវិស័យ ក្រសួង ស្ថាប័នត្រូវរៀបចំកិច្ចពិភាក្សាឲ្យបានគ្រប់គ្រាន់ជាមួយអ្នកពាក់ព័ន្ធ រួមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ វិស័យឯកជន និងសង្គមស៊ីវិលក្នុងដំណើរការនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ។ក្រសួង ស្ថាប័នក៏ត្រូវពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍដែលពាក់ព័ន្ធក្នុងការកំណត់អាទិភាពនានាដែលអាចទទួលបានការគាំទ្រ។ អាទិភាពទាំងនេះ ត្រូវបង្កើតឡើងផ្ទៃក្នុងនិងត្រូវមានសង្គតិភាពជាមួយអាទិភាពជាតិ ទិសដៅយុទ្ធសាស្ត្រ និងគោលបំណងដែលមានចែងនៅក្នុងផ.យ.អ.ជ.។ ការចូលរួមរបស់ដៃគូអភិវឌ្ឍ គឺដើម្បីទទួលបានយោបល់ស្តីពីការអភិវឌ្ឍតាមវិស័យ ដែលនឹងអាចទទួលបានការគាំទ្រ។

### ខ. ដំណើរការនៃការអនុម័តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ

នៅថ្នាក់ជាតិ ប្រធានស្ថាប័នតាមវិស័យត្រូវផ្តល់ការអនុម័តលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យបន្ទាប់ពីការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ។ ក្នុងករណីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យណាជាផែនការដែលមានលក្ខណៈអន្តរវិស័យ ប្រធានស្ថានប័នតាមវិស័យដែលពាក់ព័ន្ធនឹងអនុម័តរួមគ្នាលើផែនការនោះ។

## ២.៣ ការរៀបចំស្ថាប័នសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ

### ក្រសួង ស្ថាប័ន

ក្រសួង ស្ថាប័នត្រូវបង្កើតក្រុមការងារមួយសម្រាប់ទទួលខុសត្រូវក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យរបស់ខ្លួន។ ក្រុមការងារនេះ ត្រូវមានសមាសភាពពីមន្ត្រីទទួលបន្ទុកផែនការ មន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុ មន្ត្រីបច្ចេកទេសថ្នាក់ប្រធាននាយកដ្ឋានរបស់ក្រសួង ស្ថាប័ននិងតំណាងរបស់ដៃគូអភិវឌ្ឍ។ ក្រុមការងារនេះ មានតួនាទីធ្វើសុខដុមនីយកម្ម សម្របសម្រួល តាមដានត្រួតពិនិត្យ វាយតម្លៃ និងធ្វើរបាយការណ៍ស្តីពីចក្ខុវិស័យនិងគោលដៅរបស់វិស័យ ក្របខ័ណ្ឌគោលនយោបាយ ផែនការ និងការសម្រេចបានរបស់វិស័យ។

លក្ខន្តិកៈរបស់ក្រុមការងារ មានដូចខាងក្រោម៖

១. រៀបចំកិច្ចពិភាក្សាលើបញ្ហាគោលនយោបាយនិងយុទ្ធសាស្ត្រពីគ្រប់អ្នកចូលរួម ដែលពាក់ព័ន្ធក្នុងវិស័យ។
២. រៀបចំនិងសម្របសម្រួលយុទ្ធសាស្ត្រវិស័យសម្រាប់ផែនការវិនិយោគនិងថវិការយៈពេលវែង មធ្យម និងខ្លី។
៣. រៀបចំសូចនាករនិងតាមដានត្រួតពិនិត្យនិងវាយតម្លៃការសម្រេចបានរបស់វិស័យ។
៤. ធ្វើអាទិភាពចំណាយសម្រាប់ធនធានដែលមាន និងកៀរគរធនធានសម្រាប់បំពេញបន្ថែមក្នុងដំណើរការអនុវត្តកម្មវិធីនិងគម្រោងរបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ។
៥. តាមដានត្រួតពិនិត្យនិងវាយតម្លៃកម្មវិធីនិងគោលនយោបាយរបស់វិស័យ។

### ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានកិច្ចសហការជាមួយក្រសួងផែនការត្រូវ៖

- ពង្រឹងការផ្សារភ្ជាប់ទៅនឹងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ និងការចំណាយលើកម្មវិធីដែលបានអនុម័ត។
- សម្របសម្រួលការត្រួតពិនិត្យនិងការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំនិងថវិកា។
- ធានាថាគោលការណ៍ណែនាំស្ដីពីថវិកាប្រចាំឆ្នាំឆ្លុះបញ្ចាំងពីអាទិភាពនានាដែលមានចែងក្នុងផ.យ.អ.ជ.។
- ផ្តល់ការវិភាជថវិកាដល់ក្រសួង ស្ថាប័ន ដែលមានផែនការសកម្មភាពប្រចាំឆ្នាំឆ្លុះបញ្ចាំងអាទិភាពនានាដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យរបស់ខ្លួននិងមានសង្គតិភាពជាមួយផ.យ.អ.ជ.។

### ក្រសួងផែនការ

ក្រសួងផែនការត្រូវដឹកនាំការងារសម្របសម្រួលការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ តាមរយៈសកម្មភាពដូចខាងក្រោម៖

- ផ្តល់ការណែនាំសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ ដើម្បីធានាឲ្យមានសង្គតិភាពរវាងយុទ្ធសាស្ត្រ កម្មវិធី និងសកម្មភាពរបស់វិស័យជាមួយគោលដៅអភិវឌ្ឍន៍ជាតិ។
- ផ្តល់ការគាំទ្របច្ចេកទេសតាមដែលអាចធ្វើបានដល់ក្រសួង ស្ថាប័ន សម្រាប់ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ។
- រៀបចំសិក្ខាសាលាស្តីពីការប្រើប្រាស់គោលការណ៍ណែនាំស្តីពីរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ។
- តាមដានការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ ដើម្បីធានាថាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យត្រូវបានបញ្ចប់ក្នុងរយៈពេលនៃការរៀបចំផែនការ ដែលបានកំណត់នៅក្នុងគោលការណ៍ណែនាំនេះ។

## ទីប្រឹក្សា

ដើម្បីពង្រឹងសមត្ថភាពរៀបចំផែនការនិងធានាភាពជាម្ចាស់ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ ត្រូវរៀបចំដោយក្រុមការងារនៅតាមក្រសួង ស្ថាប័ន។ ក្នុងករណីក្រសួង ស្ថាប័នពុំមានសមត្ថភាពបច្ចេកទេសគ្រប់គ្រាន់ទាក់ទងនឹងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យដូចមានចែងក្នុងគោលការណ៍ណែនាំនេះ ក្រសួង ស្ថាប័នអាចជួលទីប្រឹក្សាដែលមានជំនាញពាក់ព័ន្ធឲ្យមកជួយរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យនេះ។ ទីប្រឹក្សា ត្រូវជួយដល់ក្រុមការងារដើម្បីរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ និងមិនត្រូវរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យឲ្យពួកគេឡើយ នេះគឺជាលក្ខខ័ណ្ឌមួយ ដែលត្រូវចែងនៅក្នុងលក្ខន្តិកៈការងាររបស់ទីប្រឹក្សា ដើម្បីធានាថាក្រសួង ស្ថាប័នពង្រឹងសមត្ថភាពខាងក្នុង និងភាពជាម្ចាស់ក្នុងដំណើរការរៀបចំ។

# ជំពូកទី៣

# ដំណើរការនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ

## ៣.១ ទម្រង់របស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ

ដើម្បីគាំទ្រដល់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យដែលមានសុខដុមនីយកម្ម និងការតាមដានត្រួតពិនិត្យនិងវាយតម្លៃដោយប្រសិទ្ធភាពលើការអនុវត្តផ.យ.អ.ជ.តាមរយៈផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ គោលការណ៍ណែនាំនេះផ្តល់ទម្រង់ស្តង់ដារបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ ដែលមានមាតិកាដូចក្នុងប្រអប់ខាងក្រោម៖

ប្រអប់ទី១ : ទម្រង់ស្តង់ដារបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ

| |
|---|
| តារាងមាតិកា |
| បញ្ជីអក្សរបំព្រួញ |
| បញ្ជីតារាង |
| បញ្ជីរូបភាព |
| បុព្វកថា |
| ខ្លឹមសារសង្ខេប |
| ជំពូកទី១ : សេចក្តីផ្តើម |
| ជំពូកទី២ : ការវិភាគស្ថានភាព (សមិទ្ធផលនិងបញ្ហាប្រឈម) |
| ជំពូកទី៣ : ទិសដៅយុទ្ធសាស្ត្ររបស់វិស័យ |
| ជំពូកទី៤ : ការរៀបចំស្ថាប័នសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ |
| ជំពូកទី៥ : យុទ្ធសាស្ត្រគៀរគរហិរញ្ញប្បទានសម្រាប់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ |
| ជំពូកទី៦ : ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ |
| ជំពូកទី៧ : សេចក្តីសន្និដ្ឋាន |
| ឧបសម្ព័ន្ធទី១ : ម៉ាទ្រីចស្តីពីតម្រូវការចំណាយ |
| ឧបសម្ព័ន្ធទី២ : ម៉ាទ្រីចស្តីពីការតាមដានត្រួតពិនិត្យការអនុវត្ត |

ការពិពណ៌នាលម្អិតសម្រាប់ផ្នែកនីមួយៗមានដូចខាងក្រោម៖

*បុព្វកថា*

- ពិពណ៌នាអត្រាកំណើនរបស់វិស័យធៀបនឹងកំណើនប្រជាជនសម្រាប់ផែនការមុន ដើម្បីកំណត់ថាតើវិស័យមានកំណើនវិជ្ជមានឬធ្លាក់ចុះ។

- ប្រៀបធៀបការចូលរួមចំណែករបស់វិស័យទៅនឹងកំណើនឬការធ្លាក់ចុះ តាមអនុវិស័យផ្សេងៗ
- ពិពណ៌នាការសម្រេចបានរបស់វិស័យធៀបនឹងចំណុចដៅដែលបានកំណត់ក្នុងផែនការមុន
- ពិពណ៌នាការសម្រេចរបស់វិស័យធៀបនឹងចំណុចដៅសកលលោក ដូចជាគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ការចូលរួមចំណែករបស់ជាតិក្នុងការអនុវត្តអនុសញ្ញាក្របខណ្ឌសហប្រជាជាតិ ក្រោមកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ ឬកម្មវិធីសកលលោកផ្សេងទៀត។
- ព្យាករណ៍សម្រាប់ផែនការបន្ទាប់ ដូចមានចែងនៅក្នុងផ.យ.អ.ជ.។
- បញ្ជាក់អំពីគោលបំណងរួមរបស់ផ.យ.អ.វ. និងពិពណ៌នាអំពីយុទ្ធសាស្ត្រ និងគោលនយោបាយអភិវឌ្ឍន៍តាមវិស័យ ភាពជោគជ័យក្នុងការអនុវត្តផែនការមុន និងដំណោះស្រាយសម្រាប់បញ្ហាដែលនៅសេសសល់ ប្រសិនបើមាន សម្រាប់ដោះស្រាយនៅក្នុងផែនការបន្ទាប់។
- បញ្ជាក់អំពីគោលបំណងយុទ្ធសាស្ត្ររបស់វិស័យ ដែលមានសង្គតិភាពជាមួយអាទិភាពវិស័យនៅក្នុងផ.យ.អ.ជ.។
- រៀបរាប់បញ្ហាប្រឈមចម្បងៗយ៉ាងតិច៤ក្នុងការអភិវឌ្ឍវិស័យនិងដំណោះស្រាយសម្រាប់បញ្ហាប្រឈមទាំងនេះ។
- បញ្ជាក់អំពីស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្តផែនការ ស្ថាប័នពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធផ្សេងទៀតដែលបានចូលរួមក្នុងការរៀបចំផ.យ.អ.វ.និងការគាំទ្រសម្រាប់ការអនុវត្តផ.យ.អ.វ.។

បុព្វកថាសម្រាប់ផ.យ.អ.វ.ត្រូវចុះហត្ថលេខាដោយរដ្ឋមន្ត្រីទទួលបន្ទុកវិស័យមួយឬលើសពីមួយប្រសិនបើជាផែនការដែលមានលក្ខណៈអន្តរវិស័យ។

## *ខ្លឹមសារសង្ខេប*

ខ្លឹមសារសង្ខេបត្រូវរួមបញ្ចូលចំណុចមួយចំនួនដូចខាងក្រោម៖

- ប្រវត្តិនៃការរៀបចំផ.យ.អ.វ. រួមទាំងការពិពណ៌នាសង្ខេបអំពីដំណើរការ និងការចូលរួមរបស់អ្នកពាក់ព័ន្ធសំខាន់។
- ការគ្របដណ្តប់ និងទិសដៅរបស់គោលនយោបាយអភិវឌ្ឍន៍ កម្មវិធី និងគម្រោងនានា និង
- ថវិកា និងលទ្ធផលរំពឹងទុករបស់វិស័យ

## *ជំពូកទី១ សេចក្តីផ្តើម*

ជំពូកទី១ ត្រូវរួមបញ្ចូលចំណុចមួយចំនួនដូចខាងក្រោម៖

- សាវតា
- អាទិភាពសម្រាប់ការអភិវឌ្ឍក្នុងវិស័យ
- ទំនាក់ទំនងរវាងផ.យ.អ.វ.ជាមួយផ.យ.អ.ជ.
- បេសកម្ម និងគោលបំណងយុទ្ធសាស្ត្ររបស់វិស័យ
- ដំណើរការនៃការរៀបចំផ.យ.អ.វ.
- ទម្រង់របស់ផ.យ.អ.វ.

## ជំពូកទី២ ការវិភាគស្ថានភាព (សមិទ្ធផល និងបញ្ហាប្រឈម)

ជំពូកទី២ ត្រូវដាក់បញ្ចូលចំណុចខាងក្រោម៖

- ស្ថានភាពរបស់វិស័យយោងតាមអាណត្តិរបស់ស្ថាប័ននៅក្នុងវិស័យ ជាពិសេស ក្រសួង ស្ថាប័ននីមួយៗត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់នូវចំណុចខាងក្រោម៖
  - ការវិភាគស្ថានភាពនៃការសម្រេចបានការអនុវត្តកម្មវិធីនិងគម្រោងនៅក្នុងផែនការមុន
  - ការវិភាគភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុនៅក្នុងវិស័យនីមួយៗ ហានិភ័យសង្គមសេដ្ឋកិច្ច និងបរិស្ថានផ្សេងៗទៀត និងគំនិតផ្តួចផ្តើមដែលមានស្រាប់ ដើម្បីដោះស្រាយភាពងាយរងគ្រោះទាំងនោះ។
  - សេចក្តីសង្ខេបអំពីបញ្ហាប្រឈមនានាក្នុងការអនុវត្តកម្មវិធីនិងគម្រោងនៅក្នុងផែនការមុន
- សមត្ថភាពស្ថាប័នរបស់វិស័យ លើ៖
  - ធនធានហិរញ្ញវត្ថុ--សមាមាត្រនៃធនធានហិរញ្ញវត្ថុដែលត្រូវបានវិភាជសម្រាប់ក្រសួង ស្ថាប័ននៅក្នុងថវិកាជាតិ
  - ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្ស ដោយយោងតាមសមត្ថភាពបច្ចេកទេស
- ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ
  - តួនាទីរបស់ផែនការតាមដានត្រួតពិនិត្យនិងវាយតម្លៃរបស់វិស័យ
  - រចនាសម្ព័ន្ធសម្របសម្រួលក្នុងវិស័យដែលមានស្រាប់ និង
  - ប្រព័ន្ធព័ត៌មានដែលកំពុងដំណើរការក្នុងការគាំទ្រការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃ

## ជំពូកទី៣ ទិសដៅយុទ្ធសាស្ត្ររបស់វិស័យ

ជំពូកទី៣ ត្រូវដាក់បញ្ចូលខ្លឹមសារសំខាន់ៗដូចខាងក្រោម៖

- ចក្ខុវិស័យ និងបេសកកម្មរបស់ក្រសួង ស្ថាប័ន
- គោលបំណងយុទ្ធសាស្ត្រ និងលទ្ធផល
- អាទិភាពរបស់វិស័យបែងចែកតាមកម្មវិធីនិងអនុកម្មវិធី
- សង្គតិភាពរវាងផ.យ.អ.វ. ជាមួយ ផ.យ.អ.ជ.និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា
- អាទិភាពអន្តរវិស័យ ដូចជាយេនឌ័រ ការប្រែប្រួលអាកាសធាតុ និងកំណើនបៃតង

## ជំពូកទី៤ ការរៀបចំស្ថានប័នសម្រាប់អនុវត្តផ.យ.អ.វ.

ជំពូកទី៤ ត្រូវពិពណ៌នាចំណុចខាងក្រោម៖

- ការរៀបចំសម្រាប់សម្របសម្រួលការអនុវត្តផ.យ.អ.វ. សម្រាប់ក្នុងក្រសួងនិងអន្តរក្រសួង។
- ការរៀបចំប្រកបដោយចីរភាព--ពិពណ៌នាអំពីចីរភាពរបស់ស្ថាប័ន កម្មវិធី និងថវិកា។

## ជំពូកទី៥ យុទ្ធសាស្ត្រហិរញ្ញប្បទានសម្រាប់ផ.យ.អ.វ.

ជំពូកទី៥ ត្រូវបង្ហាញអំពីផែនការថវិកា រួមទាំងយុទ្ធសាស្ត្រកៀរគរធនធាននិងការចំណាយ ដោយដាក់បញ្ចូល៖

- ការប៉ាន់ស្មានហិរញ្ញប្បទានលើថវិកាជាតិនិងថវិកាពីដៃគូអភិវឌ្ឍ

- គម្លាតធនធានដែលត្រូវការនិងយុទ្ធសាស្ត្រក្នុងការកៀរគរធនធានបន្ថែមសម្រាប់បំពេញគម្លាតនេះ
- ការប៉ាន់ស្មានចំណាយប្រចាំឆ្នាំ (ចំណាយមូលធននិងចំណាយចរន្ត) របស់កម្មវិធីអាទិភាពនិងចំណាយរបស់ផែនការទាំងមូល (ចំណាយមូលធននិងចំណាយចរន្ត)
- ទំនាក់ទំនងផែនការហិរញ្ញវត្ថុរបស់វិស័យជាមួយចំណាយប៉ាន់ស្មានរបស់ផយអជនិងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម
- ចំណាយរបស់ផ.យ.អ.វ.នីមួយៗត្រូវផ្អែកលើការប៉ាន់ស្មានចំណាយច្បាស់លាស់ដែលមានទំនាក់ទំនងជាមួយសូចនាករ និងប្រភពធនធាន។

### *ជំពូកទី៦ ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ*

ជំពូកទី៦ ត្រូវពិពណ៌នាចំណុចខាងក្រោម៖

- និយមន័យច្បាស់លាស់លើសូចនាករជាតុចូល សូចនាករជាតុចេញ សូចនាករលទ្ធផល និងសូចនាករឥទ្ធិពល
- កាលបរិច្ឆេទនៃកិច្ចប្រជុំផ្ទៃក្នុងក្រសួង ស្ថាប័ន ដើម្បីវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តផែនការ
- កាលបរិច្ឆេទនៃការវាយតម្លៃប្រចាំឆ្នាំជាមួយគ្រប់អ្នកពាក់ព័ន្ធ
- កាលបរិច្ឆេទនៃការវាយតម្លៃពាក់កណ្តាលអាណត្តិ
- កាលបរិច្ឆេទនៃការវាយតម្លៃបញ្ចប់ការអនុវត្តផែនការ

កាលបរិច្ឆេទនៃការវាយតម្លៃបញ្ចប់ការអនុវត្តផ.យ.អ.វ. ត្រូវកំណត់ឲ្យបានច្បាស់លាស់ដើម្បីធានាថាលទ្ធផលនៃការវាយតម្លៃនេះគាំទ្រដល់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃផ.យ.អ.ជ.។

### *ជំពូកទី៧ សេចក្តីសន្និដ្ឋាន*

## ៣.៣ ដំណាក់កាលនៃការរៀបចំផ.យ.អ.វ.

ការរៀបចំផយអវមានចំនួន០៩ដំណាក់កាល ដូចខាងក្រោម៖

១. ការវិភាគវិស័យ
២. ការរៀបចំគោលនយោបាយរបស់វិស័យ
៣. ការជ្រើសរើសគោលបំណងនិងអាទិភាពរបស់វិស័យ
៤. ការរៀបចំកម្មវិធី និងអនុកម្មវិធី
៥. ការរៀបចំការប៉ាន់ស្មានចំណាយនិងក្របខ័ណ្ឌហិរញ្ញប្បទាន
៦. ការរៀបចំប្រព័ន្ធតាមដាន
៧. ការរៀបចំសេចក្តីព្រាង
៨. ការកែសម្រួលសេចក្តីព្រាង
៩. ការអនុម័ត និងការផ្សព្វផ្សាយ

គ្រប់ដំណាក់កាលតម្រូវឲ្យមានជំនាញបច្ចេកទេស ប៉ុន្តែត្រូវមានការជូនដំណឹងនិងពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនិងដៃគូអភិវឌ្ឍក្នុងដំណើរការនៃការរៀបចំផ.យ.អ.វ. ជាពិសេសនៅចុងដំណាក់កាលទី៣ និងទី៧។ ដំណាក់កាលទី១និងទី៤ ត្រូវចំណាយពេលច្រើន ដោយសារតម្រូវឲ្យមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ

ចំណែកដំណាក់កាលទី៥ ត្រូវការតែអ្នកបច្ចេកទេស ដែលទទួលខុសត្រូវសម្រាប់ការបំពេញតម្រូវការចំណាយតាមផ្នែករបស់ខ្លួន។ លទ្ធផលនៃដំណាក់កាលទី១ដល់ទី៦ ត្រូវបានប្រើប្រាស់សម្រាប់ជាធាតុចូលដល់សមាសភាគនៃទម្រង់ផ.យ.អ.វ.ខាងលើ។ ការបញ្ចប់ដំណាក់កាលទាំង៩ ជាទូទៅចំណាយពេលប្រហែល៣ទៅ៤ខែ។

## ៣.២.១ ដំណាក់កាលទី១ ការវិភាគវិស័យ

### ការវិភាគអំពីបរិបទ

ការវិភាគអំពីបរិបទ ត្រូវបង្ហាញអំពីទិដ្ឋភាពម៉ាក្រូសេដ្ឋកិច្ច ប្រជាសាស្ត្រ វប្បធម៌ សង្គមកិច្ច ការប្រែប្រួលអាកាសធាតុ បរិស្ថាន នយោបាយ និងស្ថាប័ន។ ការវិភាគអំពីទិដ្ឋភាពម៉ាក្រូសេដ្ឋកិច្ច ត្រូវបញ្ជាក់ពីនិន្នាការកំណើនសេដ្ឋកិច្ចពីអតីតនិងអនាគត ចំណូលរបស់រដ្ឋ និងនិន្នាការការងារ។ ផ្នែកប្រជាសាស្ត្រ ត្រូវបញ្ជាក់អំពីប្រជាជនដែលចូលរួមក្នុងវិស័យ ដង់ស៊ីតេប្រជាជន និងការធ្វើចំណាកស្រុក។ ផ្នែកវប្បធម៌ សង្គមកិច្ចត្រូវបញ្ជាក់អំពីឥទ្ធិពលរបស់វិស័យឬការទទួលរងឥទ្ធិពលដោយភាពខុសគ្នាផ្នែកទ្រព្យសម្បត្តិនិងវប្បធម៌ រួមទាំងយេនឌ័រ ចំណែកផ្នែកនយោបាយនិងស្ថាប័នត្រូវផ្តោតលើតួនាទីរបស់រាជរដ្ឋាភិបាលនិងវិស័យឯកជន រដ្ឋបាលរបស់ស្ថាប័ន និងបញ្ហាវិមជ្ឈការរបស់សកម្មភាពវិស័យ បើមាន។ ការវិភាគអំពីការប្រែប្រួលអាកាសធាតុ និងទិដ្ឋភាពបរិស្ថានផ្សេងទៀត ត្រូវកំណត់ពីហានិភ័យរយៈពេលខ្លីនិងវែង និងកាលានុវត្តភាពសម្រាប់ការងារធន់នឹងអាកាសធាតុនៅតាមវិស័យ ព្រមទាំងបង្កើនប្រសិទ្ធភាពធនធាន និងកាត់បន្ថយផលប៉ះពាល់លើបរិស្ថាន។

### ការវិភាគអំពីគោលនយោបាយដែលមានស្រាប់

ផ្នែកនេះត្រូវវិភាគអំពីគោលនយោបាយដែលមានឥទ្ធិពលលើវិស័យ ដូចជាគោលនយោបាយនានាដែលមាននៅក្នុងការសម្រេចរបស់រាជរដ្ឋាភិបាល គោលនយោបាយអភិវឌ្ឍន៍ធំៗ ដែលមានឥទ្ធិពលផ្ទាល់លើការអនុវត្តរបស់វិស័យ ជាពិសេសគោលនយោបាយ ដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ព្រមទាំងការប្តេជ្ញាចិត្តអន្តរជាតិនានាដែលរាជរដ្ឋាភិបាលបានទទួលយក ដូចជាផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុកម្ពុជាការចូលរួមចំណែករបស់ជាតិក្នុងការអនុវត្តអនុសញ្ញាក្របខណ្ឌសហប្រជាជាតិ និងគោលនយោបាយនិងយុទ្ធសាស្ត្រស្តីពីកំណើនបៃតង។

### ការវិភាគអំពីការអនុវត្តរបស់វិស័យ

ការវិភាគនេះត្រូវបញ្ជាក់អំពីគុណភាពនិងការទទួលបានធាតុចេញរបស់វិស័យដោយសមធម៌ ប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធក្នុងការផលិតធាតុចេញរបស់វិស័យ និងត្រូវមានសូចនាករច្បាស់លាស់សម្រាប់វាស់វែងនិងប្រើប្រាស់ក្នុងការវិភាគនិងតាមដានសកម្មភាពរបស់វិស័យ។ ការវិភាគត្រូវដាក់បញ្ចូលសូចនាករ ដែលទាក់ទងនឹងសមត្ថភាពរបស់វិស័យដើម្បីដោះស្រាយបញ្ហាអន្តរវិស័យនានា រួមទាំងការប្រែប្រួលអាកាសធាតុ ដើម្បីជៀសវាងការលំអៀងធំពេកលើវិស័យ និងទទួលបានការវិភាគដែលផ្តោតលើភស្តុតាង ក្រសួង ស្ថាប័នតាមវិស័យអាចជួលអ្នកវិភាគខាងក្រៅមកជួយធ្វើការវិភាគវិស័យរបស់ខ្លួន។

### ការវិភាគអំពីសមត្ថភាពគ្រប់គ្រង

ផ្នែកនេះត្រូវធ្វើការវិភាគលើសមត្ថភាពរបស់ក្រសួង ស្ថាប័នក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន និងដោះស្រាយបញ្ហាប្រឈមរបស់វិស័យខ្លួន រួមទាំងហានិភ័យនៃការប្រែប្រួលអាកាសធាតុប្រកបដោយប្រសិទ្ធភាព និងភាពខ្លាំងនិងភាពខ្សោយរបស់ក្រសួង ស្ថាប័ននៅគ្រប់កម្រិតក្នុងការផលិតជាតុចេញ ព្រមទាំងការកំណត់បញ្ហាប្រឈមសំខាន់ៗ ដែលត្រូវដោះស្រាយដើម្បីធានាការអនុវត្តរបស់វិស័យប្រកបដោយប្រសិទ្ធភាពនិងភាពស័ក្តិសិទ។ ការវិភាគអំពីសមត្ថភាពគ្រប់គ្រងត្រូវរួមបញ្ចូលព័ត៌មានស្តីពីតម្រូវការសមត្ថភាព ដើម្បីបង្កើនការឆ្លើយតបរបស់វិស័យទៅការប្រែប្រួលអាកាសធាតុ រួមទាំងការគាំទ្រពីក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការគ្រប់គ្រងហានិភ័យអាកាសធាតុ (ឧទាហរណ៍ ការវាយតម្លៃរួមគ្នាស្តីពីហានិភ័យអាកាសធាតុ ការត្រួតពិនិត្យរួមគ្នា ការរៀបចំគោលនយោបាយឆ្លើយតបនានា ដែលមានការសម្របសម្រួលរួមគ្នា ជាដើម)។

### ការវិភាគអំពីចំណាយនិងប្រភពហិរញ្ញប្បទាន

ការវិភាគអំពីចំណាយនិងប្រភពហិរញ្ញប្បទានរបស់កម្មវិធីនានារបស់វិស័យត្រូវបញ្ចូលការវិភាគការចំណាយសាធារណៈតាមក្រុមចំណាយនិងប្រភពហិរញ្ញប្បទាន។ សម្រាប់វិស័យណាដែលបានធ្វើវិមជ្ឍការការទទួលខុសត្រូវក្នុងការផ្តល់សេវាវិស័យទៅថ្នាក់ក្រោមជាតិ វិស័យនោះក៏ត្រូវធ្វើការវិភាគអំពីការចំណាយនិងប្រភពហិរញ្ញប្បទានដោយថ្នាក់ក្រោមជាតិសម្រាប់ការងារនេះផងដែរ។ លើសពីនេះទៀត ការវិភាគក៏គួរតែពិចារណាអំពីការវិនិយោគរបស់វិស័យដែលពាក់ព័ន្ធលើហានិភ័យអាកាសធាតុ ឬភាពធន់នឹងអាកាសធាតុនៅក្នុងវិស័យរបស់ខ្លួនផងដែរ។

### ការរៀបចំលទ្ធផលនៃការវិភាគ

ការវិភាគព័ត៌មានចេញពីដំណាក់កាលវិភាគវិស័យត្រូវរៀបចំជាមាតិកានៅក្នុងជំពូកទី២នៃផ.យ.អ.វ. ដែលមាន៣ជំហាន ដូចខាងក្រោម៖

#### *ជំហានទី១៖ ការត្រួតពិនិត្យអំពីការអនុវត្តរបស់វិស័យ*

ការត្រួតពិនិត្យអំពីការអនុវត្តរបស់វិស័យត្រូវបញ្ជាក់អំពី៖

- គោនយោបាយ កម្មវិធី និងសកម្មភាពដែលទាក់ទងនឹងអាទិភាពនានានៅក្នុងផ.យ.អ.ជ.មុន
- អន្តរាគមន៍នានា ដែលមិនមាននៅក្នុងផ.យ.អ.ជ. ប៉ុន្តែត្រូវបានអនុវត្តក្នុងរយៈពេលនៃផ.យ.អ.ជ.មុន
- ការអនុវត្តបញ្ហាអន្តរវិស័យនានា ដូចជាយេនឌ័រ បរិស្ថាន ប្រជាជន និងកម្មវិធីគាំពារសង្គមនានា
- របាយការណ៍ចំណូលនិងចំណាយរបស់វិស័យ
- បញ្ហាប្រឈមនានាក្នុងពេលអនុវត្តផែនការ
- បទពិសោធនិងមេរៀន សម្រាប់ការរៀបចំផ.យ.អ.ជ.បន្ទាប់

#### *ជំហានទី២៖ ការរៀបចំទិន្នន័យមូលដ្ឋានរបស់វិស័យ*

ផ្អែកលើទិន្នន័យដែលមាន ក្រសួង ស្ថាប័នត្រូវរៀបចំទិន្នន័យមូលដ្ឋានរបស់វិស័យខ្លួន ដែលរួមមាន៖

- ការពិពណ៌នាអំពីហេដ្ឋារចនាសម្ព័ន្ធនិងធនធានមនុស្សសម្រាប់ការអភិវឌ្ឍវិស័យ
- ការវិភាគអំពីផលិតកម្មនិងការបែងចែងសេវារបស់វិស័យ

- ការវិភាគអំពីបញ្ហាអន្តរវិស័យ
    - ✓ *យេនឌ័រ*--ការតួនាទីនិងការទទួលខុសត្រូវរបស់បុរស ស្ត្រី ក្មេងប្រុស និងក្មេងស្រី និងការទទួលបានសេវាផ្សេងៗ
    - ✓ *បរិស្ថាន*
        - ការប្រែប្រួលអាកាសធាតុ--ការវាយតម្លៃអំពីឥទ្ធិពលរយៈពេលវែងនិងមធ្យមនៃការប្រែប្រួលអាកាសធាតុលើកំណើនតាមវិស័យ និងកំណត់កាលានុវត្តភាពសម្រាប់ភាពធន់នឹងអាកាសធាតុនៃការវិនិយោគរបស់វិស័យ និងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់
        - ទឹកជំនន់
        - គ្រោះរាំងស្ងួត
        - បញ្ហាបរិស្ថានជាមួយផ្នែកវិស័យថាមពល
        - ការបំពុលខ្យល់
        - ការបំពុលទឹក
        - ការបំពុលសំឡេង
        - ការបំពុលដី
        - ការនេសាទ
        - ការកាប់បំផ្លាញព្រៃឈើ
        - ការបាត់បង់ជីវៈជម្រុះ
        - ការធ្វើអាជីវកម្មរ៉ែ
        - ការហូរច្រោះដី
        - ការគ្រប់គ្រងកាកសំណល់(កាកសំណល់វេជ្ជសាស្ត្រ កាកសំណល់មានជាតិពុល សំរាម កាកសំណល់អេឡិចត្រូនិច)
- សូចនាករសម្រាប់ការអភិវឌ្ឍតាមវិស័យ--សូចនាករសម្រាប់វាស់វែងការសម្រេចបានរបស់វិស័យត្រូវកំណត់និងបង្ហាញជាទិន្នន័យមូលដ្ឋានសម្រាប់ផ.យ.អ.វ. ដែលទាក់ទងនឹងសូចនករដែលមានចែងក្នុងផ.យ.អ.ជ.។ លើសពីនេះទៀត ក្រសួង ស្ថាប័ន ត្រូវបញ្ចូលសូចនាកររបស់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលទាក់ទងនឹងវិស័យរបស់ខ្លួន និងសូចនាករដែលវាស់វែងអំពីវឌ្ឍនភាពនៃការដោះស្រាយហានិភ័យការប្រែប្រួលអាកាសធាតុ និងគម្លាតសមត្ថភាពដែលបានកំណត់។ សូចនាករទាំងនេះគឺជាមូលដ្ឋានសម្រាប់កំណត់ចំណុចដៅដែលត្រូវសម្រេចបាននៅក្នុងផ.យ.អ.វ.និងការវាយតម្លៃសមិទ្ធផល។ សូចនាករគួរតែបំបែងតាមភេទ តំបន់ (ជាតិ តំបន់ ទីប្រជុំជន ជនបទ និងស្រុក) ប្រសិនអាចធ្វើទៅបាន។

### *ជំហានទី៣៖ ការផ្សារភ្ជាប់បញ្ហាអភិវឌ្ឍន៍សំខាន់ៗទៅនឹងផ.យ.អ.ជ.*

បញ្ហាអភិវឌ្ឍន៍ដែលបានកំណត់នៅក្នុងជំហាទី២ ត្រូវផ្សារភ្ជាប់ជាមួយនឹងបញ្ហាអភិវឌ្ឍន៍ដែលកំណត់នៅក្នុងអំឡុងពេលអនុវត្តផ.យ.អ.ជ.មុននិងត្រូវរៀបចំជាគោលនយោបាយធៀបនឹងផ.យ.អ.ជ.បន្ទាប់ ដើម្បីជានា

ថាបញ្ហាប្រឈមដែលបានកំណត់ក្នុងផ.យ.អ.ជ.ត្រូវបានដោះស្រាយនៅផ.យ.អ.វ.។ ធាតុចេញសំខាន់របស់ជំហានទី៣គឺម៉ាទ្រីចដែលបង្ហាញអំពីទំនាក់ទំនងរបស់បញ្ហានៅក្នុងផ.យ.អ.វ.និងផ.យ.អ.ជ.។

តារាងទី១ : ទំនាក់ទំនងរវាងគោលដៅអភិវឌ្ឍន៍សំខាន់ៗជាមួយផ.យ.អ.ជ.

| អាទិភាពក្នុងផ.យ.អ.ជ. | គោលដៅអភិវឌ្ឍន៍តាមវិស័យ |
|---|---|
| អាទិភាពទី១: .... | ១. |
| | ២. |
| | ៣. |
| អាទិភាពទី២: .... | ១. |
| | ២. |
| | ៣. |

### ៣.២.២ ដំណាក់កាលទី២ ការរៀបចំគោលនយោបាយ

ការរៀបចំគោលនយោបាយត្រូវកំណត់គោលដៅរយៈពេលវែង ដែលអាចលើសរយៈពេលរបស់ផែនការ និងជ្រើសរើសយុទ្ធសាស្ត្រ ដើម្បីសម្រេចបានគោលដៅទាំងនេះ និងមានមូលដ្ឋានលើការពិនិត្យឡើងវិញនូវគោលនយោបាយដែលមានស្រាប់និងលទ្ធផលនៃការវិភាគវិស័យដែលផ្តោតលើ៖

- គោលនយោបាយនានាដែលមាននៅក្នុងការសម្រេចរបស់រាជរដ្ឋាភិបាល
- គោលនយោបាយអភិវឌ្ឍន៍ធំៗ ដែលមានឥទ្ធិពលផ្ទាល់លើការអនុវត្តរបស់វិស័យ ជាពិសេសគោលនយោបាយដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
- ការប្តេជ្ញាចិត្តអន្តរជាតិនានាដែលរាជរដ្ឋាភិបាលបានទទួលយក ដូចជាគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងពិធីសារផ្សេងៗ

### ៣.២.៣ ដំណាក់កាលទី៣ ការជ្រើសរើសគោលបំណង និងកម្មវិធីនៅតាមវិស័យ

គោលការណ៍ទូទៅសម្រាប់រៀបចំគោលបំណងនិងកម្មវិធីអាទិភាពគឺការប្រើឧបករណ៍មួយ ដែលមានឈ្មោះថា *ដើមឈើបញ្ហា* ដែលជួយក្នុងការវិភាគនិងកំណត់អាទិភាពបញ្ហានានានៅជុំវិញបញ្ហាសំខាន់មួយ។ ដោយធ្វើការផ្លាស់ប្តូរពាក្យទៅជា *ដើមឈើគោលបំណង* យើងនឹងអាចកំណត់បាននូវចក្ខុវិស័យ គោលដៅ គោលបំណង និងធាតុចេញនៅតាមវិស័យនីមួយៗ។

ការរៀបចំដើមឈើបញ្ហា គឺជាវិធីសាស្ត្រមួយដែលតម្រូវឲ្យមានកិច្ចសកហាការគ្នានិងត្រូវបានប្រើប្រាស់សម្រាប់ការពិភាក្សាជាក្រុមនិងមានការឯកភាពជាក្រុមក្នុងការកំណត់បញ្ហា និងឥទ្ធិពលនានារបស់បញ្ហាសំខាន់មួយដែលបានជួយដល់ការយល់ដឹងអំពីបរិបទ និងទំនាក់ទំនងរបស់បញ្ហានិងឥទ្ធិពលនានា ដែលអាចកើតមាននៅពេលអនុវត្តសកម្មភាពនានា។

ចក្ខុវិស័យរបស់វិស័យ ត្រូវមានសង្គតិភាពជាមួយចក្ខុវិស័យរបស់ជាតិមានលក្ខណៈទូលាយដើម្បីគ្របដណ្តប់លើតួនាទីនិងភារៈកិច្ចរបស់ក្រសួង ស្ថាប័ន និងងាយយល់។ ក្រសួង ស្ថាប័ននីមួយៗត្រូវកំណត់គោលដៅ

មួយដែលទាក់ទងនឹងគោលដៅរបស់ផ.យ.អ.ជ.។ គោលដៅរបស់វិស័យ ត្រូវឆ្លុះបញ្ចាំងអំពីអាទិភាពរបស់ផ.យ.អ.ជ.។ គោលដៅរបស់វិស័យនិងគោលដៅជាតិត្រូវមានលក្ខណៈអាចប្រៀបធៀបបាន ដើម្បីធានាអំពីសង្គតិភាព។ ក្នុងករណីដែលមិនមានសង្គតិភាពជាមួយគ្នា គោលដៅវិស័យ ត្រូវធ្វើការកែសម្រួលឡើងវិញ ដើម្បីឆ្លុះបញ្ចាំងអំពីគោលដៅដែលកំណត់សម្រាប់វិស័យនីមួយៗនៅក្នុងផ.យ.អ.ជ.។

គោលដៅ គោលបំណង និងកម្មវិធីតាមវិស័យដែលពាក់ព័ន្ធត្រូវរួមចំណែកដោះស្រាយហានិភ័យនៃការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ និងកំណត់កាលានុវត្តភាព ដើម្បីចូលរួមចំណែកដល់កំណើនបៃតង និងកំណើនកាបូនទាបដែលធន់នឹងអាកាសធាតុ។

## ៣.២.៤ ជំហានទី៤ ការរៀបចំកម្មវិធីអាទិភាពរបស់វិស័យ

ក្រសួង ស្ថាប័ន ត្រូវរៀបចំកម្មវិធីអាទិភាពរបស់ខ្លួនដើម្បីសម្រេចគោលដៅរបស់វិស័យដែលជួយដល់ការសម្រេចបានគោលដៅរបស់ជាតិ។ កម្មវិធីគឺជាបណ្តុំនៃគម្រោង សេវា សកម្មភាព ដែលចូលរួមចំណែកផ្ទាល់ដល់ការសម្រេចបានគោលបំណងរបស់វិស័យនៅក្នុងពេលវេលាមួយជាក់លាក់។ ក្រសួង ស្ថាប័នត្រូវកំណត់អាទិភាពគោលបំណង និងចង្កោមសកម្មភាពឬសកម្មភាពរបស់ខ្លួនដោយមានការឯកភាពគ្នានៅក្នុងក្រសួងស្ថាប័ន។ ការកំណត់អាទិភាព គួរផ្តោតលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

- ឥទ្ធិពលលើប្រជាជន ជាពិសេសប្រជាជនក្រីក្រនិងងាយរងគ្រោះ
- ឥទ្ធិពលលើការសម្រេចបានតម្រូវការមូលដ្ឋានរបស់ប្រជាជន ដូចជា សុខភាពមាតានិងកុមារ គុណភាពអប់រំ ការកាត់បន្ថយការរើសអើងយេនឌ័រ ជាដើម
- ឥទ្ធិពលលើសេដ្ឋកិច្ច ដូចជាការទាក់ទាញការវិនិយោគ ការបង្កើតការងារ កំណើនប្រាក់ចំណូល ជាដើម
- ការលុបបំបាត់គម្លាតរវាងទីប្រជុំជននិងតំបន់ជនបទក្នុងការទទួលបានសេវាសាធារណៈ
- ការដោះស្រាយបញ្ហាអន្តរវិស័យ

កម្មវិធីអាទិភាពរបស់វិស័យត្រូវដាក់បញ្ចូលសកម្មភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ដូចជាគោល-នយោបាយ ឧបករណ៍ហិរញ្ញវត្ថុ ឧបករណ៍ផែនការ ការប្រមូលទិន្នន័យនិងប្រព័ន្ធតាមដាន ការវិនិយោគលើភាពធន់នឹងអាកាសធាតុ គម្រោងសាកល្បង និងការស្រាវជ្រាវ ជាដើម និងវិធានការកាត់បន្ថយគ្រោះមហន្តរាយនានា។ កម្មវិធីអាទិភាពរបស់វិស័យនឹងគ្របដណ្តប់លើកាលានុវត្តភាពនានា សម្រាប់ការកែលម្អប្រសិទ្ធភាពធនធាន សមភាពយេនឌ័រ និងបរិយាបន្នសង្គម និងគុណភាពបរិស្ថាន។

### ៣.២.៤.១ ការរៀបចំកម្មវិធីនិងតារាងក្របខ័ណ្ឌតក្កៈ

គោលការណ៍ក្របខ័ណ្ឌតក្កៈត្រូវបានប្រើប្រាស់សម្រាប់រៀបចំកម្មវិធី។ គោលការណ៍ក្របខ័ណ្ឌតក្កៈគឺជាវិធីមួយសម្រាប់វិភាគបញ្ហា កំណត់គោលបំណង និងជ្រើសរើសនិងរៀបចំយុទ្ធសាស្ត្រនិងសកម្មភាពពាក់ព័ន្ធដើម្បីសម្រេចបានគោលបំណងនានាតាមលំដាប់ ហើយបង្កើតបានជាតារាងក្របខ័ណ្ឌតក្កៈ ដែលផ្តល់ព័ត៌មានសង្ខេបអំពីកម្មវិធីនិងអមដោយផែនការសកម្មភាពលម្អិត។ តារាងទី២ បង្ហាញអំពីរចនាសម្ព័ន្ធរបស់តារាងក្របខ័ណ្ឌតក្កៈ។

### តារាងទី២ : រចនាសម្ព័ន្ធនិងមាតិការបស់តារាងក្របខ័ណ្ឌតក្កៈ

| ការពិពណ៌នាអំពីកម្មវិធី | សូចនាករ | វិធីសាស្ត្រផ្ទៀងផ្ទាត់ | ការសន្មត់ |
|---|---|---|---|
| **គោលដៅ**<br>ឥទ្ធិពលនៃការអភិវឌ្ឍដែលកើតចេញពីកម្មវិធីនៅកម្រិតជាតិនិងវិស័យ | រង្វាស់ទៅលើការចូលរួមចំណែកក្នុងការសម្រេចបានគោលដៅ | ប្រភពព័ត៌មាននិងវិធីសាស្ត្រប្រើប្រាស់ក្នុងការប្រមូលនិងរាយការណ៍ | |
| **លទ្ធផល**<br>លទ្ធផលនៅពេលចប់កម្មវិធីជាពិសេសផលប្រយោជន៍រំពឹងទុកដល់ក្រុមគោលដៅ | ជួយឆ្លើយសំណួរ *តើយើងអាចដឹងថាលទ្ធផលសម្រេចបានឬអត់តាមរបៀបណា ?* គួរបញ្ចូលព័ត៌មានលម្អិតអំពីបរិមាណ គុណភាព និងពេលវេលា | ប្រភពព័ត៌មាននិងវិធីសាស្ត្រប្រើប្រាស់ក្នុងការប្រមូលនិងរាយការណ៍ | ការសន្មត់ (កត្តាខាងក្រៅការគ្រប់គ្រង របស់គម្រោង) ដែលអាចមាន ឥទ្ធិពលលើ លទ្ធផល |
| **ធាតុចេញ**<br>ធាតុចេញគឺជាលទ្ធផលផ្ទាល់ដែលកម្មវិធីផលិតបាន (ទំនិញឬសេវា) និងស្ថិតក្រោមការគ្រប់គ្រងរបស់គម្រោង | ជួយឆ្លើយសំណួរ *តើយើងអាចដឹងថាធាតុចេញសម្រេចបានឬអត់តាមរបៀបណា ?* គួរបញ្ចូលព័ត៌មានលម្អិតអំពីបរិមាណ គុណភាព និងពេលវេលា | ប្រភពព័ត៌មាននិងវិធីសាស្ត្រប្រើប្រាស់ក្នុងការប្រមូលនិងរាយការណ៍ | ការសន្មត់ (កត្តាខាងក្រៅការគ្រប់គ្រង របស់គម្រោង) ដែលអាចមានឥទ្ធិពលលើធាតុចេញ |
| **សកម្មភាព**<br>សកម្មភាពជាក់លាក់ដែលត្រូវអនុវត្ត ដើម្បីសម្រេចបាន ធាតុចេញ | **ធាតុចូល**<br>ធនធានមនុស្ស ថវិកា បរិក្ខារ ដែលត្រូវការសម្រាប់អនុវត្តសកម្មភាពនានា | | |

### សូចនាករ

សូចនាករគឺជារង្វាស់ដែលប្រើប្រាស់សម្រាប់បង្ហាញការផ្លាស់ប្តូរស្ថានភាពមួយ ឬវឌ្ឍនភាពរបស់សកម្មភាពគម្រោង ឬកម្មវិធី។ សូចនាករល្អត្រូវបំពេញលក្ខណៈវិច្ឆ័យ **SMART** ដូចខាងក្រោម៖

- **S = Specific** - ជាក់លាក់ ច្បាស់លាស់អំពីអ្វីដែលត្រូវសម្រេចបាន
- **M = Measurable** - អាចវាស់វែងបាន ដែលតម្រូវឲ្យមានតួលេខ
- **A= Achievable** - ដែលអាចសម្រេចបាន ដោយប្រើប្រាស់ធនធានមនុស្ស បរិក្ខារ ថវិកាដែលមាន
- **R = Relevant** - ដែលមានប្រយោជន៍ដល់ការសម្រេចបានគោលដៅ
- **T = Time-bound** - ដែលមានពេលវេលាកំណត់ក្នុងការសម្រេចបាន

សូចនាករផ្តល់ជាមូលដ្ឋានសម្រាប់វាយតម្លៃការសម្រេចបានគោលដៅ និងដើរតួនាទីសំខាន់សម្រាប់ការងារត្រួតពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តផ.យ.អ.វ.។

### ប្រភេទសូចនាករ

នៅក្នុងតារាងក្របខ័ណ្ឌតក្កៈ សូចនាករត្រូវបានចាត់ថ្នាក់ទៅតាមទំនាក់ទំនងនៅក្នុងចង្វាក់លទ្ធផល ដូចជាឥទ្ធិពល លទ្ធផល ធាតុចេញ និងសកម្មភាព (ធាតុចូល) នៅក្នុងការរៀបចំកម្មវិធីដូចមានក្នុងរូបភាពទី៣ខាងក្រោម។

រូបភាពទី៤ : ចង្វាក់លទ្ធផល

**ធាតុចូល** → **សកម្មភាព** → **ធាតុចេញ** → **លទ្ធផល** → **ឥទ្ធិពល**

- **សូចនាករឥទ្ធិល** ទាក់ទងនឹងគោលដៅរបស់កម្មវិធី ដែលវាស់វែងលទ្ធផលឬការផ្លាស់ប្តូររយៈពេលវែង។
- **សូចនាករលទ្ធផល** ទាក់ទងនឹងគោលបំណងរបស់កម្មវិធី ដែលវាស់វែងលទ្ធផលរយៈពេលមធ្យមដែលកើតចេញពីធាតុចេញនានា។
- **សូចនាករធាតុចេញ** ទាក់ទងនឹងលទ្ធផលផ្ទាល់របស់កម្មវិធី ដែលវាស់វែងលទ្ធផលភ្លាមៗដែលកើតចេញពីការអនុវត្តសកម្មភាពនិងការប្រើប្រាស់ធាតុចូល។
- **សូចនាករធាតុចូល** ទាក់ទងនឹងសកម្មភាព ដែលវាស់វែងធនធានមនុស្ស ថវិកា និងធនធានផ្សេងៗទៀត ដែលផ្តល់សម្រាប់អនុវត្តផែនការ។

សូចនាករនឹងត្រូវកំណត់នៅតាមកម្មវិធី ដែលជាមូលដ្ឋានសម្រាប់ដំណើរការតាមដានការអនុវត្តកម្មវិធី ប៉ុន្តែសម្រាប់គោលបំណងនៃការតាមដានការអនុវត្តផ.យ.អ.វ. តម្រូវឲ្យមានសូចនាករមួយចំនួនកំណត់ប៉ុណ្ណោះ។ ការជ្រើសរើសសូចនាករ ត្រូវពិចារណាអំពីតម្រូវការដូចខាងក្រោម៖

- ពាក់ព័ន្ធទៅនឹងលទ្ធផលនិងឥទ្ធិពលនៃការអនុវត្តផ.យ.អ.វ.
- សូចនាការត្រូវមានចំនួនកំណត់។ សូចនាករច្រើនពេកនឹងធ្វើឲ្យមានការពិបាកក្នុងការបកស្រាយ និងធ្វើឲ្យមានការភាន់ច្រឡំ និងត្រូវចំណាយថវិកាច្រើន។
- ផ្តល់ព័ត៌មានលម្អិតអំពីការសម្រេចបានរបស់វិស័យ ដោយផ្តោតលើបញ្ហាប្រឈមសំខាន់ៗ ដូចបានឆ្លុះបញ្ចាំងក្នុងកម្មវិធីអាទិភាពនានា រួមទាំងរំលេចសូចនាករដែលពាក់ព័ន្ធនឹងការប្រែប្រួល អាកាសធាតុ ការកាត់បន្ថយគ្រោះមហន្តរាយ និងកំណើនបៃតង ជាដើម។
- ផ្តល់ព័ត៌មានអំពីការសម្រេចបានជាមធ្យមនៅថ្នាក់ជាតិនិងអំពីវិសមភាពនៅក្នុងការអនុវត្តរបស់វិស័យ។
- បញ្ជីនិងនិយមន័យសូចនាករត្រូវរក្សាទុកដដែលនៅក្នុងរយៈពេលនៃផែនការ (ទោះបីអាចមានការកែសម្រួលពាក្យពេជន៍ខ្លះក៏ដោយ) ដើម្បីមានលទ្ធភាពវាស់វែងវឌ្ឍនភាពដោយមានសង្គតិភាពជាមួយគ្នា។
- សូចនាករត្រូវងាយយល់ ជាពិសេសអ្នកសម្រេចចិត្តនិងអ្នកប្រើប្រាស់ទូទៅ។
- ដើម្បីធានាឲ្យមានការសម្របសម្រួលនិងកិច្ចសហប្រតិបត្តិការល្អ ក្រុមអ្នករៀបចំផ.យ.អ.វ.ត្រូវធានាថាសូចនាករទាំងអស់បានទទួលការឯកភាពគ្នាពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់និងដៃគូអភិវឌ្ឍ។

### ៣.២.៤.២ នីតិវិធីក្នុងការត្រួតពិនិត្យតាមដាន

នីតិវិធីក្នុងការត្រួតពិនិត្យតាមដានផ.យ.អ.វ. គឺជាដំណើរការមួយដែលចាប់ផ្តើមពីការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំនៅឆ្នាំទី១ និងបន្តរហូតដល់ការរៀបចំផ.យ.អ.វ.បន្ទាប់ ដូចមានបង្ហាញក្នុងរូបភាពទី៥ខាងក្រោម។

រូបភាពទី៥ : នីតិវិធីក្នុងការត្រួតពិនិត្យតាមដានផ.យ.អ.វ.




*I. ការរៀបចំផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ*

ផែនការប្រតិបត្តិប្រចាំឆ្នាំគឺជាលក្ខខណ្ឌចាំបាច់ដំបូងសម្រាប់ការអនុវត្តផ.យ.អ.វ.ដោយជោគជ័យ និងត្រូវរៀបចំឡើងដោយផ្អែកលើកម្មវិធី ដោយនាយកដ្ឋានទាំងអស់ដែលទទួលខុសត្រូវក្នុងការអនុវត្តកម្មវិធីទាំងនោះ។ ដើម្បីធានាបាននូវការអនុវត្តផែនការប្រកបដោយប្រសិទ្ធភាព ផែនការប្រតិបត្តិប្រចាំឆ្នាំនិងថវិកាប្រចាំឆ្នាំត្រូវមានការផ្សារភ្ជាប់គ្នាដោយជិតស្និត។

ផែនការប្រតិបត្តិប្រចាំឆ្នាំត្រូវមានទម្រង់និងក្របខ័ណ្ឌតក្កៈ ដូចផែនការរយៈពេលមធ្យម ប៉ុន្តែមានលក្ខណៈលម្អិតជាង និងមានបញ្ជាក់ចំណុចខាងក្រោម៖

- ចំណុចដៅច្បាស់លាស់ដែលត្រូវសម្រេចបាន
- សកម្មភាពលម្អិតដែលត្រូវអនុវត្តដើម្បីសម្រេចបានចំណុចដៅ
- ពេលវេលាសម្រាប់សកម្មភាពនីមួយៗ
- នាយកដ្ឋានឬអង្គភាព ដែលទទួលខុសត្រូវក្នុងការអនុវត្ត និង
- ការប៉ាន់ស្មានថវិកាជាក់ស្តែង និងពេលវេលាដែលត្រូវការថវិកា ដោយបានគិតគូរការដាក់បញ្ចូលចំណាយដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ

### II. *ការត្រួតពិនិត្យតាមដានជាប្រចាំ*

ការអនុវត្តផែនការត្រូវមានការត្រួតពិនិត្យតាមដានជាប្រចាំ តាមរយៈការប្រជុំជាមួយនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធទាំងអស់ ដោយផ្អែកលើចំណុចដៅនិងសូចនាករដែលមាននៅក្នុងផែនការសកម្មភាព។

### III. *ការវាយតម្លៃតាមពេលកំណត់*

នាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ ត្រូវរៀបចំជារបាយការណ៍វាយតម្លៃវឌ្ឍនភាពទៅតាមពេលវេលាកំណត់ទៅតាមគោលការណ៍ណែនាំនិងឧបករណ៍ដែលបានផ្តល់ជូន។

### IV. *ការវាយតម្លៃប្រចាំឆ្នាំ*

ក្នុងត្រីមាសទី៤នៃឆ្នាំសារពើពន្ធ ក្រសួង ស្ថាប័នត្រូវរៀបចំជារបាយការណ៍វាយតម្លៃសមិទ្ធផលប្រចាំឆ្នាំរួមមួយ ដោយផ្អែកលើរបាយការណ៍ដែលផ្តល់ដោយនាយកដ្ឋានជាអ្នកអនុវត្ត និងជាតុចូលផ្សេងៗទៀត ដូចជារបាយការណ៍ហិរញ្ញវត្ថុ ជាដើម ដែលផ្តល់ដោយនាយកដ្ឋានពាក់ព័ន្ធផ្សេងទៀត។

របាយការណ៍វាយតម្លៃនេះនឹងត្រូវប្រើជាឯកសារមូលដ្ឋានសម្រាប់ប្រជុំវាយតម្លៃប្រចាំឆ្នាំជាមួយគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ដែលនឹងផ្តល់ឱកាសសម្រាប់ការវាយតម្លៃសមិទ្ធផលនិងបញ្ហាប្រឈមក្នុងការអនុវត្តផែនការរួមគ្នា និងផ្តល់ការឯកភាពលើការកែលម្អផ្សេងៗ ដើម្បីសម្រេចបានគោលដៅនិងចំណុចដៅដែលមានចែងនៅក្នុងផ.យ.អ.វ.។ កិច្ចប្រជុំវាយតម្លៃប្រចាំឆ្នាំត្រូវកំណត់ពេលវេលាមួយ ដែលអាចលទ្ធផលនៃកិច្ចប្រជុំនេះធ្វើជាមូលដ្ឋានសម្រាប់រៀបចំផែនការប្រតិបត្តិនិងថវិកាប្រចាំឆ្នាំសម្រាប់ឆ្នាំបន្ទាប់។

### V. *ការវាយតម្លៃពាក់កណ្តាលអាណត្តិ*

ការវាយតម្លៃពាក់កណ្តាលអាណត្តិត្រូវបានរៀបចំឡើង ដើម្បីពិនិត្យមើលសមិទ្ធផលដែលសម្រេចបាន និងបញ្ហាប្រឈមដែលជួបប្រទះក្នុងពេលអនុវត្ត និងសម្រេចថាតើត្រូវកែសម្រួលចំណុចដៅនិងកម្មវិធីសម្រាប់ពាក់កណ្តាលអាណត្តិនៃផែនការ។ ការវាយតម្លៃពាក់កណ្តាលអាណត្តិក៏ត្រូវពិនិត្យមើលថាតើបញ្ហាប្រឈមសំខាន់ៗ ដែលបានកំណត់តាមវិស័យត្រូវបានដោះស្រាយប្រកបដោយប្រសិទ្ធភាពឬទេ ដោយត្រូវស្នើឡើងនូវវិធានការឬកម្មវិធីកែតម្រូវតាមការចាំបាច់។ បន្ថែមលើរបាយការណ៍វាយតម្លៃវឌ្ឍនភាពដែលផលិតដោយក្រសួង ស្ថាប័ន គួរមានការសិក្សាវាយតម្លៃពិសេសមួយ ដើម្បីធ្វើការវាយតម្លៃកម្មវិធីដែលបានបញ្ចប់និងកំពុងដំណើរការជាលក្ខណៈប្រព័ន្ធ និងបង្កើតជាមេរៀននិងបទពិសោធន៍ចេញពីការសិក្សាទាំងនោះសម្រាប់ការរៀបចំផែនការ និងកម្មវិធីនាពេលខាងមុខ។

### VI. *ការវាយតម្លៃចុងបញ្ចប់*

របាយការណ៍វាយតម្លៃសមិទ្ធផលចុងបញ្ចប់ និងការសិក្សាវាយតម្លៃត្រូវត្រួតពិនិត្យមើលផែនការទាំងមូល។ របាយការណ៍វាយតម្លៃចុងក្រោយនេះ ដែលត្រូវដាក់ពិភាក្សានៅក្នុងកិច្ចប្រជុំវាយតម្លៃចុងបញ្ចប់ជាមួយគ្រប់អ្នកពាក់ព័ន្ធត្រូវផ្តោតលើលទ្ធផលនិងឥទ្ធិពល ផលប្រយោជន៍ ប្រសិទ្ធភាពចំណាយ និងចីរភាព រួមទាំងការវិភាគអំពីកត្តាដែលនាំឲ្យការសម្រេចបានសមិទ្ធផលនិងបរាជ័យក្នុងការសម្រេចបានសមិទ្ធផល ដើម្បីរៀបចំជាមេរៀនសម្រាប់ការកែលម្អគោលនយោបាយនិងការរៀបចំផ.យ.អ.វ.បន្ទាប់។

## ៣.៣ ពេលវេលាសម្រាប់រៀបចំផ.យ.អ.វ.

ការរៀបចំផ.យ.អ.វ. ត្រូវចាប់ផ្តើមដំណើរការរៀបចំនៅពេលចាប់ផ្តើមវដ្តនៃការរៀបចំផែនការថ្មី នៅពេលក្រសួងផែនការចេញសេចក្តីជូនដំណឹងដល់គ្រប់ក្រសួង ស្ថាប័ន ដើម្បីរៀបចំនិងផ្ញើជាតុចូលមកក្រសួងផែនការ សម្រាប់រៀបចំផ.យ.អ.ជ.។ ព័ត៌មានដែលផ្តល់មកក្រសួងផែនការត្រូវជាលទ្ធផលនៃដំណាក់កាលទី១ ការវិភាគវិស័យ ដំណាក់កាលទី២ ការរៀបចំគោលនយោបាយ និងដំណាក់កាលទី៣ ការជ្រើសរើសគោលបំណងនិងអាទិភាពតាមវិស័យ។ ផ.យ.អ.ជ.ដែលបានអនុម័តរួច ផ្តល់ជាមូលដ្ឋានគ្រឹះសម្រាប់ដំណាក់កាលទី៤ ការរៀបចំកម្មវិធីអាទិភាព ដំណាក់កាលទី៥ ការរៀបចំចំណាយនិងក្របខ័ណ្ឌហិរញ្ញប្បទាន និងដំណាក់កាលទី៦ ការរៀបចំការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។ពេលវេលាសម្រាប់ការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃត្រូវរៀបចំឲ្យបានត្រឹមត្រូវការកំណត់នៅក្នុងផ.យ.អ.ជ.។

តារាងទី៣ : សកម្មភាពនិងពេលវេលាសម្រាប់រៀបចំផ.យ.អ.វ.

| ដំណាក់កាល | បរិយាយ | ពេលវេលា | សម្គាល់ |
|---|---|---|---|
| ១ | ការវិភាគវិស័យ | ៣ សប្តាហ៍ | តម្រូវឲ្យមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ ដូចជាក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល និងវិស័យឯកជន |
| ២ | ការរៀបចំគោលនយោបាយរបស់វិស័យ | ៣ សប្តាហ៍ | |
| ៣ | ការជ្រើសរើសគោលបំណងនិងអាទិភាពរបស់វិស័យ | ២ សប្តាហ៍ | |
| ៤ | ការរៀបចំកម្មវិធី និងអនុកម្មវិធី | ២ សប្តាហ៍ | ត្រូវផ្អែកលើអាទិភាពនានាដែលចែងក្នុង ផ.យ.អ.ជ. |
| ៥ | ការរៀបចំការប៉ាន់ស្មានចំណាយនិងក្របខ័ណ្ឌហិរញ្ញប្បទាន | ២ សប្តាហ៍ | |
| ៦ | ការរៀបចំប្រព័ន្ធតាមដាន | ២ សប្តាហ៍ | |
| ៧ | ការរៀបចំសេចក្តីព្រាង | ២ សប្តាហ៍ | ត្រូវចែករំលែកជាមួយអ្នកពាក់ព័ន្ធ ដើម្បីស្នើសុំការផ្តល់យោបល់ |
| ៨ | ការកែសម្រួលសេចក្តីព្រាង | ៤ សប្តាហ៍ | ត្រូវរៀបចំកិច្ចពិគ្រោះយោបល់ជាមួយគ្រប់អ្នកពាក់ព័ន្ធ |
| ៩ | ការអនុម័ត និងការផ្សព្វផ្សាយ | ៤ សប្តាហ៍ | អនុម័តដោយប្រធានក្រសួងឬស្ថាប័ន ហើយបន្ទាប់ពីទទួលបានការអនុម័ត ផែនការនេះត្រូវផ្សព្វផ្សាយនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសម្រាប់ជាការណែនាំដល់ការជ្រើសរើសកម្មវិធីនានាសម្រាប់ការរៀបចំផែនការអភិវឌ្ឍន៍របស់ខ្លួន |

# ជំពូកទី៤

# ដំណើរការអនុវត្តផ.យ.អ.វ.

## ៤.១ ការទទួលខុសត្រូវសម្រាប់ការអនុវត្តផ.យ.អ.វ.

ការអនុវត្តផ.យ.អ.វ.គឺជាការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ននៅតាមវិស័យ រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល និងវិស័យឯកជន។ ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំផ.យ.អ.វ. ដែលមានគោលដៅ គោលបំណងយុទ្ធសាស្ត្រ និងកម្មវិធីរបស់វិស័យ ដែលបន្សីុជាមួយគោលបំណងរបស់ផ.យ.អ.ជ.។

## ៤.២ សង្គតិភាពរវាងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមជាមួយផ.យ.អ.ជ.និងផ.យ.អ.វ.

ការរៀបចំផ.យ.អ.វ. និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមត្រូវផ្អែកលើអាទិភាពនានានៅក្នុងផ.យ.អ.ជ.។ ដំណើរការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ត្រូវផ្តោតលើការវិភាគលើគោលបំណងនិងអាទិភាពជាតិដែលមានចែងក្នុងផ.យ.អ.ជ. ដែលផ្តល់ជាមូលដ្ឋានសម្រាប់រៀបចំបេសកកម្ម និងគោលបំណងរបស់ក្រសួង ស្ថាប័ន។ ថវិកានៅក្នុងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ត្រូវបានរៀបចំឡើងដោយផ្អែកលើចំណាយរបស់ផែនការសកម្មភាពប្រចាំឆ្នាំនៅក្នុងផ.យ.អ.ជ.។ ដូចនេះ រយៈពេលព្យាករណ៍ក្នុងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមត្រូវដូចគ្នាជាមួយរយៈពេលរបស់ផ.យ.អ.ជ.និងផ.យ.អ.វ.។

## ៤.៣ ការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ

គោលនយោបាយនិងកម្មវិធីរបស់វិស័យត្រូវបំបែកជាសកម្មភាពរួចដាក់បញ្ចូលក្នុងផែនការសកម្មភាពប្រចាំឆ្នាំរួមជាមួយនិងថវិកា បំបែកទៅតាមក្រសួង ស្ថាប័ននៅតាមវិស័យ។ ការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំត្រូវផ្តោតលើចំណុចខាងក្រោម៖

- សកម្មភាពដែលត្រូវអនុវត្ត
- អ្នកអនុវត្តសកម្មភាព និងពេលវេលាសម្រាប់ការអនុវត្ត
- ការចូលរួមរបស់ដៃគូអភិវឌ្ឍ និង
- ថវិកាដែលបង្ហាញអំពីចំណាយរបស់សកម្មភាពដែលបានគ្រោងទុក

### ទំនាក់ទំនងផែនការសកម្មភាពប្រចាំឆ្នាំវិស័យជាមួយថវិកាជាតិប្រចាំឆ្នាំ

ថវិកាជាតិ គឺជាឧបករណ៍សំខាន់សម្រាប់ការអនុវត្តផ.យ.អ.ជ. ហើយចំណាយរបស់ផ.យ.អ.វ.បានឆ្លុះបញ្ចាំងអំពីចំណាយប៉ាន់ស្មានដែលនឹងកើតឡើងនៅពេលអនុវត្តផ.យ.អ.ជ.។ ក្នុងន័យនេះ ផ.យ.អ.វ.ត្រូវបញ្ចូលចំណាយរបស់បុគ្គលិក រដ្ឋបាល និងសកម្មភាពវិនិយោគ ដែលចូលរួមចំណែកដល់ការសម្រេចបានគោលបំណងនានារបស់វិស័យ។ ដូចនេះ ក្រុមការងារដែលរៀបចំផ.យ.អ.វ. ត្រូវកំណត់អំពីតម្រូវការជាតុ

ចូលគ្រប់ប្រភេទ និងប៉ាន់ស្មានចំណាយសម្រាប់សកម្មភាពនីមួយៗ។ ដើម្បីធានាចំណាយរបស់សកម្មភាពប្រចាំឆ្នាំនៅក្នុងផ.យ.អ.វ.ដាក់ចូលក្នុងថវិកាជាតិ ការរៀបចំចំណាយរបស់សកម្មភាពប្រចាំឆ្នាំនៅក្នុងផ.យ.អ.វ. ត្រូវគោរពតាមដំណើរការនៃក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ដែលបានផ្សារភ្ជាប់ចំណាយរបស់វិស័យជាមួយនឹងគោលដៅ គោលបំណង សកម្មភាព ធាតុចេញ និងលទ្ធផលរបស់វិស័យទៅនឹងថវិកាជាតិ។

ដើម្បីមិនឲ្យប៉ះពាល់ដល់ពេលវេលាអនុវត្ត ចំណាយប៉ាន់ស្មានរបស់សកម្មភាពប្រចាំឆ្នាំ ត្រូវឆ្លើយតបនឹងលំហូរធនធានតាមពេលកំណត់ ដែលមាននៅក្នុងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម។

## ៤.៤ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ក្រសួង ស្ថាប័នតាមវិស័យត្រូវតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផ.យ.អ.វ.។ ប្រព័ន្ធតាមដាន ត្រួតពិនិត្យនិងវាយតម្លៃសម្រាប់វិស័យត្រូវដាក់ឲ្យដំណើរការសម្រាប់រៀបចំផែនការនិងថវិកា តាមដាន និងរាយការណ៍ ហើយពេលវេលានិងការរៀបចំសម្រាប់ការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃត្រូវចែងឲ្យបានច្បាស់លាស់នៅក្នុងផ.យ.អ.វ.។ ដើម្បីជាធាតុចូលសម្រាប់ការវាយតម្លៃជារួមនិងការវាយតម្លៃផ.យ.អ.ជ.ផងកាលបរិច្ឆេទសម្រាប់ការវាយតម្លៃផ.យ.អ.វ. ត្រូវធ្វើឡើង០២ខែមុនកាលបរិច្ឆេទការវាយតម្លៃរបស់ផ.យ.អ.ជ.។ គណកម្មការជាន់ខ្ពស់សម្រាប់ការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃ ត្រូវផ្តល់គោលការណ៍ណែនាំស្តីពីការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃ ព្រមទាំងកាលបរិច្ឆេទសម្រាប់ការវាយតម្លៃនានារបស់ផ.យ.អ.ជ.។

ប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃវិស័យនឹងត្រូវបង្កើតឡើងនិងបញ្ចូលទៅក្នុងគ្រប់ដំណាក់កាលនៃវដ្តរបស់កម្មវិធី ចាប់ពីការកំណត់រហូតដល់ការវាយតម្លៃ។ សម្រាប់រយៈពេលរបស់ផ.យ.អ.វ. ប្រព័ន្ធនេះនឹងបង្កើតរបាយការណ៍តាមពេលកំណត់ស្តីពីវឌ្ឍនភាព ដើម្បីផ្តល់ព័ត៌មានចាំបាច់ដល់អ្នកគ្រប់គ្រង ជួយឲ្យកម្មវិធីដំណើរការរលូន ជូនព័ត៌មានដល់អ្នកពាក់ព័ន្ធថាតើសកម្មភាព ដែលអនុវត្តរួចសម្រេចបានគោលបំណងរបស់វិស័យដែរឬទេ និងគូសបញ្ជាក់អំពីលទ្ធផលដែលមិនបានគ្រោងទុក។ ផ.យ.អ.វ.ទាំងអស់ត្រូវដាក់បញ្ចូលសូចនាករឲ្យបានត្រឹមត្រូវសម្រាប់វិស័យនីមួយៗ ដោយយ៉ាងហោចណាស់ត្រូវមានសូចនាករចំនួនមួយទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងសូចនាករដទៃទៀតដែលឆ្លុះបញ្ចាំងបញ្ហាអន្តរវិស័យ។ ដូចនេះ ប្រព័ន្ធតាមដាន ត្រួតពិនិត្យនិងវាយតម្លៃនឹងត្រូវដាក់បញ្ចូលតារាងតក្កៈនិងបញ្ជីសូចនាកររបស់វិស័យ។

ដើម្បីសម្រួលនិងគាំទ្រការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃដែលផ្អែកលើភស្តុតាង គ្រប់វិស័យទាំងអស់ត្រូវបង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មាន។ ប្រព័ន្ធគ្រប់គ្រងព័ត៌មាននេះមានការប្រមូល ដំណើរការ វិភាគ បកស្រាយ សរសេរ និងបង្ហាញទិន្នន័យសម្រាប់សូចនាករសំខាន់ៗ មេរៀននិងសារគោលនយោបាយដែលទាញចេញពីទិន្នន័យដែលប្រមូលបាន និងការប្រើប្រាស់មេរៀននិងសកម្មភាពគ្រប់គ្រង សម្រាប់កែលម្អការអនុវត្ត។

ឧបសម្ព័ន្ធទី១ : ម៉ាទ្រីចស្តីពីតម្រូវការចំណាយ

| បរិយាយ (កម្មវិធី អនុកម្មវិធី និងសកម្មភាព) | ចំណាយប៉ាន់ស្មាន | | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|
| | ចំណាយចរន្ត | ចំណាយវិនិយោគ | |
| | | | |
| | | | |
| | | | |

ឧបសម្ព័ន្ធទី២ : ម៉ាទ្រីចស្តីពីការតាមដានត្រួតពិនិត្យការអនុវត្ត

| សូចនាករ | ឯកតា | ២០១៧ ទិន្នន័យមូលដ្ឋាន | ២០១៨ ប៉ាន់ស្មាន | ចំណុចដៅតាមឆ្នាំ | | | | | ប្រភពទិន្នន័យ | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |